№: 35-36
30.9.97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ៣៥-៣៦ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I . រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

១៧_៩_១៩៩៧ _ អនុក្រឹត្យលេខ ៤៩ អនក្រ.បក ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការរំសាយ និងការបង្កើតទីស្នាក់ការត្រួតពិនិត្យតាមច្រកព្រំដែន និងផ្លូវគមនាគមន៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ២០៣៤

១៨_៩_១៩៩៧ _ អនុក្រឹត្យលេខ ៥០ អនក្រ.បក ស្ដីពីការបង្កើតគណៈកម្មការជាតិដើម្បីសិទ្ធិមនុស្ស ២០៣៧

១៨_៩_១៩៩៧ _ អនុក្រឹត្យលេខ ៥១ អនក្រ.បក ស្ដីពីការបង្កើតវិទ្យាល័យ នំរុន ២០៣៩

១៩_៩_១៩៩៧ _ អនុក្រឹត្យលេខ ៥២ អនក្រ.បក ស្ដីពីការសម្រួលកងពលធំលេខ៣ និងរំសាយកងពលធំលេខ ៩ ២០៤១

១៩_៩_១៩៩៧ _ អនុក្រឹត្យលេខ ៥៣ អនក្រ.បក ស្ដីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈសំរាប់ទិញឧបករណ៍ DVOR/DMG បំពាក់អោយអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ២០៤២

២២-៩-១៩៩៧ _ អនុក្រឹត្យលេខ ៥៤ អនក្រ.បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម ២០៤៣

២៣_៩_១៩៩៧ _ អនុក្រឹត្យលេខ ៥៥ អនក្រ.បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ ២០៥៧

២៣_៩_១៩៩៧ _ អនុក្រឹត្យលេខ ៥៦ អនក្រ.បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន ២០៧០

២៥_៩_១៩៩៧_ អនុក្រឹត្យលេខ ៥៧ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន ២០៨៤
២៥_៩_១៩៩៧ _ អនុក្រឹត្យលេខ ៥៨ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិសំរបសំរួលការងារអប់រំក្រៅប្រព័ន្ធ ២០៩៧
១៩_៩_១៩៩៧ _ អនុក្រឹត្យលេខ ១៨១ អនក្រ.តត ស្តីពីការប្រគល់ឋានន្តរស័ក្តិកិត្តិយស ២១០១
១៩_៩_១៩៩៧ _ អនុក្រឹត្យលេខ ១៨២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២១០២
១៩_៩_១៩៩៧ _ អនុក្រឹត្យលេខ ១៨៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២១០៣
២២_៩_១៩៩៧ _ អនុក្រឹត្យលេខ ១៨៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២១០៤
២២_៩_១៩៩៧ _ អនុក្រឹត្យលេខ ១៨៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២១០៥
២៣_៩_១៩៩៧_ អនុក្រឹត្យលេខ ១៨៦ អនក្រ.តត ស្តីពីការផ្ទេរមេដាយស្ថាបនាជាតិ ២១០៦
២៣_៩_១៩៩៧_ អនុក្រឹត្យលេខ ១៨៧ អនក្រ.តត ស្តីពីការផ្ទេរមេដាយស្ថាបនាជាតិ ២១០៧
២៣_៩_១៩៩៧_ អនុក្រឹត្យលេខ ១៨៨ អនក្រ.តត ស្តីពីការផ្ទេរមេដាយស្ថាបនាជាតិ ២១០៩
២៣_៩_១៩៩៧_ អនុក្រឹត្យលេខ ១៨៩ អនក្រ.តត ស្តីពីការផ្ទេរមេដាយស្ថាបនាជាតិ ២១១០
២៣_៩_១៩៩៧_ អនុក្រឹត្យលេខ ១៩០ អនក្រ.តត ស្តីពីការផ្ទេរមេដាយសហមេត្រី ២១១១
២៣_៩_១៩៩៧_ អនុក្រឹត្យលេខ ១៩១ អនក្រ.តត ស្តីពីការផ្ទេរមេដាយស្ថាបនាជាតិ ២១១២

២_សេចក្តីសំរេច

១៦_៩_១៩៩៧ _ សេចក្តីសំរេចលេខ ៣២ សសរ ស្តីពីការផ្ទេរសិទ្ធិ ២១១៤
១៨_៩_១៩៩៧ _ សេចក្តីសំរេចលេខ ៣៣ សសរ ស្តីពីការផ្ទេរសិទ្ធិ ២១១៥
១៨_៩_១៩៩៧ _ សេចក្តីសំរេចលេខ ៣៤ សសរ ស្តីពីការផ្ទេរសិទ្ធិ ២១១៦
១៩_៩_១៩៩៧ _ សេចក្តីសំរេចលេខ ៣៥ សសរ ស្តីពីការបង្កើតក្រុមការងារសំរាប់សំរបសំរួលកិច្ចការមាតុភូមិនិវត្តន៍នៃជនភៀសខ្លួនជនភៀសសឹកនៅតាមបណ្តោយព្រំដែន កម្ពុជា_ថៃ ២១១៧
២២_៩_១៩៩៧ _ សេចក្តីសំរេចលេខ ៣៦ សសរ ស្តីពីការផ្ទេរសិទ្ធិ ២១២០
២២_៩_១៩៩៧ _ សេចក្តីសំរេចលេខ ៣៧ សសរ ស្តីពីការផ្ទេរសិទ្ធិ ២១២១
២២_៩_១៩៩៧ _ សេចក្តីសំរេចលេខ ៣៨ សសរ ស្តីពីការផ្ទេរសិទ្ធិ ២១២២

៣_សារាចរណែនាំ

២២_៩_១៩៩៧ _ សារាចរណែនាំលេខ ០៦ សរណន ស្តីអំពីវិធានការជំរុញការងារបង្កបង្កើនផលរដូវវស្សា និងទប់ទល់គ្រោះរាំងស្ងួត ២១២៤

៤_លិខិតបញ្ជា

១៨_៩_១៩៩៧ _ លិខិតបញ្ជាលេខ ២២ បជ ២១២៦

II - ភាគរាជបណ្ណាក្រសួង

១_ទីស្តីការគណៈរដ្ឋមន្ត្រី

ប្រកាស

២២_៩_១៩៩៧ _ ប្រកាសលេខ ១៣៥ ប្រក.បល ស្តីពីការតែងតាំងមន្ត្រីរាជការ ២១៣០

២_ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

ប្រកាស

១៧_៩_១៩៩៧ _ ប្រកាសលេខ ២៥៦/៩៧ ពម.ប្រក អនុញ្ញាតអោយអ្នកស្រី ហេង ផាំង បើកអាជីវកម្ម ទូរទស្សន៍ខ្សែកាប នៅទីរួមស្រុកស្រែអំបិល ខេត្តកោះកុង ២១៣២
២៥_៩_១៩៩៨ _ ប្រកាសលេខ ២៥៧/៩៧ ពម.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ២១៣៣

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

២៩_៩_១៩៩៧ _ ប្រកាសលេខ ៧១០ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា «ស្វាយស្រណោះ» មកជាសាលាបឋមសិក្សា «ហ៊ុន សែន ស្វាយស្រណោះ» ២១៣៥
២៩_៩_១៩៩៧ _ ប្រកាសលេខ ៧១១ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា «ពាមជីកង» មកជាសាលាបឋមសិក្សា «ហ៊ុន សែន ពាម ជីកង» ២១៣៦

២៩_៩_១៩៩៧ – ប្រកាសលេខ ៧១២ អយក.ប្រក ស្ដីពីការប្ដូរឈ្មោះសាលាបឋមសិក្សា «វ៉ារិន្ទ» មកជាសាលាបឋមសិក្សា «ហ៊ុន សែន វ៉ារិន្ទ» ២១៣៨

៤_ទីស្ដីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

២៥_៩_១៩៩៧ – ប្រកាសលេខ ១៩៦ ប្រក.វវស.ប្ត ស្ដីពីការទទួលស្គាល់លទ្ធផលនៃការប្រលងសញ្ញាបត្រសិល្បៈ និងស្នាតកបត្រសិល្បៈឆ្នាំសិក្សា ១៩៩៦_១៩៩៧ ២១៤០

I - រាជរដ្ឋាភិបាល

១៣៨

១_អនុក្រឹត្យ

អនុក្រឹត្យ លេខ ៤៩ អនក្រ.បក

១៤០ ស្តីពី

ការកែសំរួលអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរំសាយ និងការបង្កើតទីស្នាក់ការត្រួតពិនិត្យតាមច្រកព្រំដែន និងផ្លូវគមនាគមន៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការរំសាយ និងការបង្កើតទីស្នាក់ការត្រួតពិនិត្យតាមច្រកព្រំដែន និងផ្លូវគមនាគមន៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- យោងតាមសភាពការណ៍ចាំបាច់

សំរេច

មាត្រា ១ .- ត្រូវបានកែសំរួលនូវបទបញ្ញត្តិមួយចំនួននៃអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរំសាយនិងការបង្កើតទីស្នាក់ការត្រួតពិនិត្យតាមច្រកព្រំដែន និងផ្លូវគមនាគមន៍ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងមាត្រា ដូចខាងក្រោម ÷

១_ មាត្រា ២ថ្មី :

ក_ អំពីផ្លូវជាតិ :

១_ ផ្លូវជាតិលេខ ១ ពីព្រំដែនបាវិត មកដល់រាជធានីភ្នំពេញមាន ០១ ចំណុច : បាវិត (ខេត្តស្វាយរៀង) ។

២_ ផ្លូវជាតិលេខ ២ ពីព្រំដែនភ្នំដិន មកដល់រាជធានីភ្នំពេញមាន ០១ ចំណុច : ភ្នំដិន (ខេត្តតាកែវ) ។

៣_ ផ្លូវជាតិលេខ ៤ ពីក្រុងព្រះសីហនុ មកដល់រាជធានីភ្នំពេញមាន ០១ ចំណុច : កំពង់ផែ ពាណិជ្ជកម្មអន្តរជាតិក្រុងព្រះសីហនុ ។

៤_ ផ្លូវជាតិលេខ៥ ពីព្រំដែនប៉ោយប៉ែត មកដល់រាជធានីភ្នំពេញមាន០១ ចំណុច: ប៉ោយប៉ែត (ខេត្តបន្ទាយមានជ័យ) ។

ឃ_ អំពីផ្លូវសមុទ្រ :

១_ ខេត្តកោះកុងមាន ០៤ចំណុច: កោះស្តេច ប៉ាក់ខ្លង ចាំយាម និងស្រែអំបិល។

២_ ក្រុងព្រះសីហនុមាន ០៣ចំណុច : កំពង់ផែពាណិជ្ជកម្មអន្តរជាតិក្រុងព្រះសីហនុ ទំនប់រលក និងស្ទឹងហាវ ។

៣_ ខេត្តកំពតមាន ០២ចំណុច : ទាន់ហាន់ និងកោះសេះ ។

៤_ ទីក្រុងកែបមាន ០១ចំណុច : ផែក្រុងកែប ។

២_ មាត្រា ៣ថ្មី :

៣_ ច្រកទ្វារតំបន់ព្រំដែន

ខេត្តកំពត

_ ទាន់ហាន់

_ កោះសេះ

ខេត្តកោះកុង

- កោះស្តេច (ដែ)
- ប៉ាក់ខ្លង (ដែ)
- ស្រែអំបិល

មាត្រា ២ .-ជំនួសអោយទីស្នាក់ការដែលបានរំសាយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសហការនឹងក្រសួងពាក់ព័ន្ធ ពង្រឹងប្រព័ន្ធត្រួតពិនិត្យរៀងៗខ្លួននៅតាមច្រកចេញចូលតាមព្រំដែន ដែលបានកំណត់រួចហើយ ។

មាត្រា ៣ .-ក្នុងករណីចាំបាច់មានគ្រោះអាសន្នកើតឡើង ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនប្រទេសទ្វេភាគី និងច្រកទ្វារតំបន់ព្រំដែនមានសិទ្ធិស្នើសុំកំលាំងនគរបាលព្រំដែន និងកងរាជអាវុធហត្ថជាតិ ដែលបោះទីតាំងនៅជិតបំផុតអោយចូលមកជួយធ្វើអន្តរាគមន៍ ។

មាត្រា ៤ .-បទបញ្ញត្តិទាំងឡាយក្រៅពីការកែសំរួលខាងលើ ហើយដែលមានចែងក្នុងអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរំសាយនិងការបង្កើតទីស្នាក់ការត្រួតពិនិត្យតាមច្រកព្រំដែន និងផ្លូវគមនាគមន៍ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅជាធរមានដដែល ។

មាត្រា ៥ .-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ ប្រចាំក្រុងកែប ប្រចាំក្រុងប៉ៃលិន និងអភិបាលគ្រប់ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្ត

អនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

* * *

អនុក្រឹត្យ លេខ ៥០ អនក្រ.បក

ស្ដីពី

ស្ដីពីការបង្កើតគណៈកម្មការជាតិ ដើម្បីសិទ្ធិមនុស្ស

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- ផ្អែកតាមស្ថានភាពជាក់ស្ដែងនិងចាំបាច់របស់ព្រះរាជាណាចក្រកម្ពុជា

សម្រេច

មាត្រា ១._ត្រូវបានបង្កើតគណៈកម្មការជាតិ ដើម្បីសិទ្ធិមនុស្ស ។ គណៈកម្មការនេះ មានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ ។

មាត្រា ២._គណៈកម្មការជាតិ ដើម្បីសិទ្ធិមនុស្ស មានបេសកកម្មប្រតិបត្តិឃ្លាំមើល និង ដោះស្រាយការរំលោភសិទ្ធិមនុស្សជាអចិន្ត្រៃយ៍ ។

មាត្រា ៣._គណៈកម្មការជាតិ ដើម្បីសិទ្ធិមនុស្ស រួមមានសមាសភាព ដូចខាងក្រោម ÷

១_លោក **ឆន សារាយ**	ប្រធានអង្គការអាត់ហុក	ប្រធាន
២_លោកស្រី **ពុង ឈីវកេច**	ប្រធានអង្គការលីកាដូ	សមាជិក
៣_លោក **ខៀវ ចំរើន**	ប្រធានគណៈកម្មាធិការសំរបសំរួលកម្ពុជា	សមាជិក
៤_ទីប្រឹក្សានាយករដ្ឋមន្ត្រីទី១		សមាជិក
៥_ទីប្រឹក្សាសម្ដេចនាយករដ្ឋមន្ត្រីទី២		សមាជិក

សមាសភាពគណៈកម្មការជាតិ ដើម្បីសិទ្ធិមនុស្សនេះ មានឋានៈការស្មើរដ្ឋមន្ត្រីទាំងប្រធាន និងសមាជិកទាំងអស់ ។

មាត្រា ៤._ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តិទៅរបស់គណៈកម្មការជាតិ ដើម្បីសិទ្ធិមនុស្ស ត្រូវកំណត់ដោយអនុក្រឹត្យមួយផ្សេងទៀត ។

មាត្រា ៥._សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ និងអស់លោក លោកស្រី ដែលមាននាមចែងក្នុងមាត្រា ៣ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ហត្ថលេខានិងត្រា	ហត្ថលេខានិងត្រា
អ៊ឹង ហួត	**ហ៊ុន សែន**

* * *

អនុក្រឹត្យ លេខ ៥១ អនក្រ.បក

ស្តីពី

ការបង្កើតមហាវិទ្យាល័យ ន័រតុន

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការបង្កើតនិងគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សាឯកទេស
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧-១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- តាមសំណើរបស់នាយកមជ្ឈមណ្ឌលបាណាណា និងក្រសួងអប់រំ យុវជន និងកីឡា

សំរេច

មាត្រា ១.– អនុញ្ញាតអោយបង្កើតមហាវិទ្យាល័យឯកជនមួយដែលមានឈ្មោះថា «**មហាវិទ្យាល័យ ន័រតុន**» មហាវិទ្យាល័យនេះមានទីតាំងនៅផ្ទះលេខ ១៥២ ផ្លូវលេខ ១០៨ សង្កាត់ផ្សារចាស់ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មាត្រា ២.– ចំពោះមុខការសិក្សានៅមហាវិទ្យាល័យ ន័រតុន មាន ៤ផ្នែក :

១_ច្បាប់	មានរយៈពេល ៤ឆ្នាំ
២_វិទ្យាសាស្ត្រសេដ្ឋកិច្ច	មានរយៈពេល ៤ឆ្នាំ
៣_ពាណិជ្ជសាស្ត្រ	មានរយៈពេល ៤ឆ្នាំ
៤_វិទ្យាសាស្ត្រកុំព្យូទ័រ	មានរយៈពេល ៤ឆ្នាំ

ទៅអនាគតមហាវិទ្យាល័យ នឹងបើកផ្នែកផ្សេងៗតាមលទ្ធភាព និងតម្រូវការសង្គម ។

មាត្រា ៣._លក្ខខណ្ឌទទួលសិស្សអោយចូលរៀន

បេក្ខជនទាំងពីរភេទជាសិស្ស និស្សិត ជាប្រជាពលរដ្ឋ និងជាមន្ត្រីរាជការ ដែលមានសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ ឬ សញ្ញាប័ត្រមានតំលៃស្មើ ។

មាត្រា ៤._លោក **ចាន់ សុខឃាង** មានភារកិច្ច :

_ជ្រើសរើសសិស្សអោយចូលរៀន និងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន ។

_គ្រប់គ្រងអោយបាននូវដំណើរការបង្រៀន ឯកសារសិក្សា ការប្រឡង និងការប្រគល់សញ្ញាប័ត្រ ។

_គោរព និងអនុវត្តតាមសារាចរ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល

_ធានាអោយបាននូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម

_រាយការណ៍រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំយុវជន និងកីឡា

មាត្រា ៥._ក្រសួងអប់រំយុវជន និងកីឡា មានសិទ្ធិធ្វើអធិការកិច្ច និងត្រួតពិនិត្យ ហើយមានសិទ្ធិស្នើសុំបិទប្រសិនបើសាលានេះអនុវត្តខុសពីច្បាប់រដ្ឋ ។

មាត្រា ៦._និស្សិតដែលរៀនចប់កម្មវិធីសិក្សា នឹងទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សានឹងបានទទួលបរិញ្ញាប័ត្រឧត្តមសិក្សា ដែលផ្តល់ដោយមហាវិទ្យាល័យ ន័រតុន ។

មាត្រា ៧._ក្រសួងអប់រំយុវជន និងកីឡា អគ្គនាយកដ្ឋាន និង អង្គភាពដែលពាក់ព័ន្ធជាមួយនឹងលោក **ចាន់ សុខឃាង** មានភារកិច្ចរៀងៗខ្លួនអនុវត្តនិងប្រតិបត្តិតាមសេចក្តីសំរេចនេះ។

មាត្រា ៨._អនុក្រឹត្យនេះមានប្រសិទ្ធភាព គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

* * *

អនុក្រឹត្យ លេខ ៥២ អនក្រ.បក

ស្ដីពីការកែសម្រួលកងពលធំលេខ ៣ និង រំសាយកងពលធំលេខ ៩

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ១៩៩៧ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា ១._ត្រូវបានកែសម្រួលកងពលធំថ្មើរជើងលេខ ៣ មកជាកងពលតូចថ្មើរជើងលេខ៣ វិញ។

មាត្រា ២._ត្រូវបានរំសាយកងពលធំថ្មើរជើងលេខ ៩ ចេញពីក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ។

មាត្រា ៣._សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង រដ្ឋលេខាធិការដ្ឋានពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ហត្ថលេខា និងត្រា	ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

អនុក្រឹត្យ លេខ ៥៣ អនក្រ.បក

ស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ សំរាប់ទិញឧបករណ៍ DVOR/DMG បំពាក់អោយអាកាសយានដ្ឋាន អន្តរជាតិពោធិចិនតុង

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១០៩៤/៩៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ១៩៩៤ និងលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ ១១ នស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល លេខ ០១សប្រក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

មាត្រា ១.- អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រើប្រាស់គណនី ឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈ ដែលត្រូវបានបង្កើតឡើងតាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ ដើម្បីទិញឧបករណ៍ DVOR/DMG បំពាក់អោយ អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ដើម្បីជានាការហោះហើរឡើងវិញ និងបំរើ អោយនយោបាយបើកចំហរជើងមេឃក្នុងវិស័យអាកាសចរជូនរដ្ឋលេខាធិការដ្ឋានអាកាស ចរស៊ីវិល មានទឹកប្រាក់ ៣.១៨៨.៩៩២ $US (បីលានមួយរយប៉ែតសិបប្រាំបីពាន់ ប្រាំបួនរយកៅសិបពីរដុល្លារអាមេរិក) ។

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ហត្ថលេខា និងត្រា	ហត្ថលេខានិងត្រា
អ៊ុង ហួត	**ហ៊ុន សែន**

* * *

អនុក្រឹត្យ លេខ ៥៤ អនក្រ.បក

ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ

របស់ក្រសួងពាណិជ្ជកម្ម

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីនាសម័យប្រជុំ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ១៩៩៧

សំរេច

ជំពូក ១

បទបញ្ញត្តិ ទូទៅ

មាត្រា ១.-អនុក្រឹត្យនេះ រៀបចំបណ្ដាអង្គភាព នៃក្រសួងពាណិជ្ជកម្ម និងកំណត់បេសកកម្មរបស់ក្រសួងនិងមុខការ នៃអគ្គាធិការដ្ឋាន អគ្គនាយកដ្ឋាន និងនាយកដ្ឋាននានា ។

ជំពូក ២

បេសកកម្ម និង ភារកិច្ចសមត្ថកិច្ច

មាត្រា២.-ក្រសួងពាណិជ្ជកម្មត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់អោយទទួលបេសកកម្មដឹកនាំ និងគ្រប់គ្រងលើវិស័យពាណិជ្ជកម្មក្នុង និងក្រៅប្រទេស នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣._ក្រសួងពាណិជ្ជកម្ម មានមុខងារ និងភារកិច្ចដូចតទៅ :

_កំណត់នយោបាយពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ។

_កំណត់អំពីសន្និធិទំនិញយុទ្ធសាស្ត្រ ។

_ត្រួតពិនិត្យថ្លៃទំនិញ និងទ្រទ្រង់ថ្លៃកសិផល ស្បៀង និងត្រួតពិនិត្យដំណើរការទីផ្សារ ។

_ចលនា និងផ្សព្វផ្សាយការប្រើប្រាស់ផលអតិថិជន និងចលនាការលក់ផលិតផលស្បៀង អាហារ វត្ថុធាតុដើម ប្រេងឥន្ធនៈ គ្រឿងឧបភោគ និងសំភារៈប្រើប្រាស់ចាំបាច់ចំពោះ សេចក្តីត្រូវការក្នុងប្រទេស និងជួយរកទីផ្សារជូនកសិករ និងធានាការផ្គត់ផ្គង់សំភារៈ បំរើ អោយកសិកម្ម និងកសិ_ឧស្សាហកម្ម ។

_ចាត់វិធានការការពារផលប្រយោជន៍អ្នកប្រើប្រាស់ ។

_រៀបចំ ដឹកនាំ និងត្រួតពិនិត្យពាណិជ្ជកម្មក្រៅប្រទេស និងផ្តល់អាជ្ញាប័ណ្ណក្នុងការនាំចេញ នាំចូលលើមុខទំនិញដែលមានក្នុងបញ្ជីកំណត់មុខទំនិញដែលហាមឃាត់ ។

_ធ្វើអោយមានតុល្យភាពទំនិញនាំចេញ នាំចូល ។

_ផ្សព្វផ្សាយ និងធ្វើទំនាក់ទំនងជាមួយទីផ្សារអន្តរជាតិ ដើម្បីលើកទិសដៅអភិវឌ្ឍន៍វិស័យ ពាណិជ្ជកម្មក្រៅប្រទេស លើមូលដ្ឋានសេដ្ឋកិច្ចទីផ្សារ ។

_សិក្សាស្រាវជ្រាវស្ថានភាពជាតិ និងអន្តរជាតិព្រមទាំងព្យាករណ៍និន្នាការទីផ្សារសំរាប់ផ្សព្វ ផ្សាយដល់ផលិតករ ពាណិជ្ជករ ដើម្បីងាយស្រួលធ្វើជំនួញនៅក្នុង ឬក្រៅប្រទេស ។

_រៀបចំ និងផ្តល់គោលការណ៍នាំចេញ នាំចូល ។

_ចេញគោលការណ៍ណែនាំអនុវត្ត និង ចាត់វិធានការក្នុងការគោរពច្បាប់ នៃការប្រកួត ប្រជែងពាណិជ្ជកម្ម និងការពារកុំអោយមានជំនួញផ្តាច់មុខពិសេសពីប្រទេសក្រៅ គ្រប ដណ្តប់ពាណិជ្ជក្នុងប្រទេសខុសច្បាប់ ។

_គ្រប់គ្រងពាណិជ្ជសញ្ញា ។

_ត្រួតពិនិត្យគុណភាព បរិមាណ ទម្ងន់ យថាប្រភេទ ទំនិញនាំចេញ នាំចូល ។ បង្ក្រាបការក្លែងបន្លំគុណភាពទំនិញនៅលើទីផ្សារ លើកលែងតែផលិតផលឱសថ បរិក្ខារ ពេទ្យ និងគ្រឿងសំអាង ។

_គ្រប់គ្រងមជ្ឈមណ្ឌលជាតិនៃប្រព័ន្ធអនុគ្រោះទូទៅ (GSP) និងធ្វើជាអាណាព្យាបាល សភាពាណិជ្ជកម្ម សហគ្រាសជំនួញរបស់រដ្ឋ ក្រុមហ៊ុនជំនួញនៃសេដ្ឋកិច្ចចំរុះរដ្ឋ និង ឯកជនដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសក្រសួងពាណិជ្ជកម្ម ។

_

_ធ្វើសហប្រតិបត្តិការសេដ្ឋកិច្ចពាណិជ្ជកម្មកម្ពុជា ជាមួយសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) និងជាមួយអង្គការអន្តរជាតិនានាដូចជា APEC-ESCAP-WIPO-EU-UNCTAD-UNCED-WTO ។ល។

_កាន់កាប់បញ្ជីពាណិជ្ជកម្ម និងគ្រប់គ្រងសមត្ថភាពពាណិជ្ជកម្មដូចមានចែងក្នុងច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ។

មាត្រា ៤ ._ក្រសួងពាណិជ្ជកម្មមានរចនាសម្ព័ន្ធដូចតទៅ :

I- ថ្នាក់កណ្តាល :

ក_ខុទ្ទកាល័យ

ខ_អគ្គាធិការដ្ឋាន

គ_អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋាននេះ មាននាយកដ្ឋានចំណុះចំនួន ០៣ គឺ :

១_នាយកដ្ឋានរដ្ឋបាល

២_នាយកដ្ឋានបុគ្គលិក

៣_នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

ឃ_អគ្គនាយកដ្ឋានបច្ចេកទេស

អគ្គនាយកដ្ឋាននេះ មាននាយកដ្ឋានចំណុះចំនួន ០៨ គឺ :

១_នាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស

២_នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស

៣_នាយកដ្ឋាន កម្ពុជាត្រួតពិនិត្យទំនិញនិហរណ៍ អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ

៤_នាយកដ្ឋាននីតិកម្ម

៥_ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

៦_នាយកដ្ឋានកម្មសិទ្ធិបញ្ញា

៧_នាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ

៨_នាយកដ្ឋានជំរុញការនាំចេញ

II - អង្គភាពមូលដ្ឋាន :

មន្ទីរពាណិជ្ជកម្មខេត្ត_ក្រុង និងរាជធានី ។

III - ក្រុមហ៊ុនរដ្ឋស្ថិតនៅក្រោមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងស្ថិ
នៅក្រោមអាណាព្យាបាលបច្ចេកទេស ក្រសួងពាណិជ្ជកម្មរួមមាន :

ក_ក្រុមហ៊ុនស្បៀងកម្ពុជា

ខ_ក្រុមហ៊ុនកម្ពុជានីហរ័ណ អាហរ័ណ និងបែងចែក (KAMPEXIM)

គ_ក្រុមហ៊ុនកសិផល រុក្ខផល

ឃ_ក្រុមហ៊ុនប្រគល់ ទទួលដឹកជញ្ជូនពាណិជ្ជកម្ម «កាំគ្រង»

ង_ក្រុមហ៊ុនសំភារៈបរិក្ខារ

ច_ក្រុមហ៊ុនស្ថាបនា

អង្គការលេខរបស់ក្រសួងពាណិជ្ជកម្ម ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

ជំពូក ៣

ខុទ្ទកាល័យរដ្ឋមន្ត្រី

មាត្រា ៥ ._ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយដែលកំណត់តាមបទបញ្ញត្តិ នៃ
អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ដូចមានយោ
ក្នុងមូលបទខាងលើស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិកា
ដ្ឋាន ។

ជំពូក ៤

អគ្គាធិការដ្ឋាន

មាត្រា ៦ ._អគ្គាធិការដ្ឋានរបស់ក្រសួងពាណិជ្ជកម្ម ទទួលបន្ទុក :

_ធ្វើអធិការកិច្ចជាប្រចាំ ទៅលើគ្រប់អង្គភាពក្រោមចំណុះក្រសួងពាណិជ្ជកម្ម ។

_ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តិទៅរបស់អង្គភាព ដែលបានធ្វើអធិការកិ
ហើយនោះ និងពីមធ្យោបាយកែលំអការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនោះ ។

_ប្រតិបត្តិភារកិច្ចតាមកាល ដែលរដ្ឋមន្ត្រីបានប្រគល់ជូន ។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប និងអមដោយ អគ្គាធិការរង ជាជំនួ
ការ ។

ឆ្នាំទី

មាត្រា

មាត្រា

មាត្រា

ជំពូក ៥

អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

មាត្រា ៧ ._ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានមុខងារដូចតទៅ :

- គ្រប់គ្រងការងាររួមមាន : រដ្ឋបាល បូកសរុប របាយការណ៍ ឯកសារ បុគ្គលិក ផែនការ ហិរញ្ញវត្ថុ សំភារៈបរិក្ខារ ការងារបណ្តុះបណ្តាល ក្របខ័ណ្ឌក្រសួង ការងារសិក្សាស្រាវជ្រាវនិងធ្វើគុណភាពការងារ ។
- សំរបសំរួលរាល់សកម្មភាពរដ្ឋបាលនៅក្នុងក្រសួង ជាមួយបណ្តាអង្គភាពមូលដ្ឋាន ខេត្ត_ក្រុង និងជាមួយបណ្តាក្រសួងនានា ។

អគ្គនាយកដ្ឋានរដ្ឋបាល នឹងហិរញ្ញវត្ថុ ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងជាជំនួយការ ។

មាត្រា ៨ ._ នាយកដ្ឋានរដ្ឋបាល ទទួលបន្ទុក :

- សំរបសំរួលរាល់កិច្ចការរបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាលជាមួយនឹងអង្គភាពមូលដ្ឋានក្រោមចំណុះ ។
- គ្រប់គ្រង និងចាត់ចែងឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល ។
- សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង ។

មាត្រា ៩ ._ នាយកដ្ឋានបុគ្គលិក ទទួលបន្ទុក :

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- រៀបចំរាល់លិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព ។
- ធ្វើកម្មវិធីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង ។
- វាយតំលៃតំរូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក ។
- រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្តដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអនុវត្តនយោបាយនោះ ។
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពតិមានប្រតិបត្តិ
- គ្រប់គ្រងការងារសង្គមរបស់ក្រសួង ។

មាត្រា ១០ .- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ទទួលបន្ទុក :

_លើកគំរោងថវិកាក្រសួង និងតាមដានរំលឹកពីការប្រតិបត្តិ ។

_ប្រមូលចំណូលអោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ ។

_ប្រមូលផ្តុំ និងសំរបសំរួលជំពូកថវិកា ។

_តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស ។

_ប្រមូលផ្តុំ និងសំរបសំរួលរាល់ចំណាយរបស់ក្រសួង ។

_គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តលទ្ធកម្មសាធារណៈ ។

_ប្រមូលផ្តុំតំរូវការធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំផ្គួសផុលសំភារៈ និងហិរ[illegible]
របស់ក្រសួង ។

_គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ ។

_ធ្វើកម្មវិធីចំណាយ បែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់ ។

_កាន់បញ្ជីជាប្រចាំនូវសាលាកប័ត្រ និងគណនេយ្យបធាតុ ។

_ពតិមានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។

_ត្រួតពិនិត្យបច្ចេកទេស នៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។

ជំពូក ៦

អគ្គនាយកដ្ឋានបច្ចេកទេស

មាត្រា ១១ .- អគ្គនាយកដ្ឋានបច្ចេកទេស ទទួលបន្ទុក :

_អនុវត្តនូវរាល់សកម្មភាពរបស់ក្រសួង ក្នុងការប្រតិបត្តិគោលនយោបាយគ្រប់[illegible]
ដឹកនាំពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស ។

_រ៉ាប់រងនូវការសំរបសំរួលខាងបច្ចេកទេសនៃកិច្ចការរបស់ក្រសួង និងអង្គភាព[illegible]
ចំណុះក្រសួង ។

_រៀបចំ និងចាត់ការបច្ចេកទេសនៃក្រសួង តាមការណែនាំទូទៅពីរដ្ឋមន្ត្រី ។

_ពិនិត្យពិច័យនិងបង្ហាញកិច្ចការសំខាន់ៗជូនជាដំណឹង និងសុំសេចក្តីសំរេចពីរដ្ឋម[illegible]

_រាយការណ៍បច្ចេកទេសចំពោះបញ្ហាសំខាន់ៗ ដែលជាមុខការរបស់រដ្ឋមន្ត្រី ។

_ពិនិត្យ និងរៀបចំឯកសារមកពីអង្គការអន្តរជាតិនានា ។

_រៀបចំឯកសារ សំរាប់ចូលរួមក្នុងសន្និសិទសេដ្ឋកិច្ចអន្តរជាតិ ។

អគ្គនាយកដ្ឋានបច្ចេកទេស ដឹកនាំដោយអគ្គនាយកមួយរូបនិងអមដោយ អគ្គនាយករងជាជំនួយការ ។

មាត្រា ១២ .- នាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស ទទួលបន្ទុក :

- កំណត់ និងបែងចែកប្រភេទទំនិញយុទ្ធសាស្ត្រ និងបន្ទាប់បន្សំ ។
- កសាង និងកំណត់តម្លៃទំនិញយុទ្ធសាស្ត្រ ។
- ក្តាប់ជាប់ និងធ្វើស្ថិតិនូវបរិមាណទំនិញចរាចរលក់ដុំ លក់រាយ នៅលើទីផ្សារក្នុងប្រទេស ។
- ក្តាប់ និងត្រួតពិនិត្យស្តុកទំនិញយុទ្ធសាស្ត្រ និងទំនិញចាំបាច់ដូចជា អង្ករ ប្រេងឥន្ធនៈ ។ល។
- សហការជាមួយផ្នែកកសិកម្ម ដើម្បីទទួលព័ត៌មាននិងក្តាប់នូវប្រភពទំនិញកសិកម្ម រុក្ខកម្ម ទាំងបរិមាណនិងគុណភាព ដើម្បីរកទីផ្សារលក់ ។
- ក្តាប់តំរូវការរបស់ផ្នែកកសិកម្ម ដើម្បីជួយជំរុញអោយមានការនាំចូលនូវមធ្យោបាយ និងឧបករណ៍ផលិតកម្ម សំរាប់បំរើអោយវិស័យនេះ ។
- សហការជាមួយផ្នែកឧស្សាហកម្ម សិប្បកម្ម ដើម្បីស្រាវជ្រាវក្តាប់នូវផលិតផលក្នុងប្រទេសដោយផ្តល់ពត៌មានអោយការផលិតសមស្រប តាមស្តង់ដារដែលអាចលក់បានលើទីផ្សារក្នុងស្រុកនិងក្រៅស្រុក ។
- ទទួលពត៌មានអំពីសកម្មភាពពាណិជ្ជកម្មនៅតាមបណ្តាខេត្ត_ក្រុង និង បូកសរុបរាយការណ៍ជូនក្រសួង ។
- លើកគំរោងនៃសេចក្តីត្រូវការរបស់ទីផ្សារក្នុងប្រទេស នូវបណ្តាមុខទំនិញសំខាន់ៗ និងចាំបាច់ ។
- លើកគំរោងផែនការ នូវបរិមាណផលិតផលសំរាប់នាំចេញនាំចូល ។
- ធ្វើគំរោងភាគកំរិត (Quota) ដោយសហការជាមួយក្រសួងពាក់ព័ន្ធ ។
- សំរង់ថ្លៃទំនិញសំខាន់ៗ និងចុះណែនាំអោយពាណិជ្ជករបិទផ្លាកតំលៃ ដើម្បីងាយស្រួលដល់អ្នកប្រើប្រាស់ ។
- ទ្រទ្រង់ថ្លៃទំនិញកសិផល ស្បៀងដែលមានសារៈសំខាន់បំរើជីវភាពរបស់ប្រជារាស្ត្រ និងសេដ្ឋកិច្ចជាតិ ។
- ត្រួតពិនិត្យការផ្សាយពាណិជ្ជកម្ម និងការប្រកួតប្រជែង ។

មាត្រា ១៣ .- នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ទទួលបន្ទុក :

- កសាងគោលនយោបាយពាណិជ្ជកម្មក្រៅប្រទេស ។
- ផ្តល់អាជ្ញាប័ណ្ណនាំចេញនាំចូល ។
- ស្រាវជ្រាវទីផ្សារ និងថ្លៃទំនិញអន្តរជាតិ ។
- ស្រាវជ្រាវលទ្ធភាពនាំចេញ ។
- សិក្សាពីតំរូវការក្នុងប្រទេស ។
- ធ្វើស្ថិតិនាំចេញនាំចូល ។
- ធ្វើកិច្ចព្រមព្រៀងទ្វេភាគី ។
- ផ្តល់ និងទទួលពត៌មានពីក្រៅ តាមរយៈស្ថានតំណាងពាណិជ្ជកម្ម ។
- រួមចំណែកគ្រប់គ្រងជំនួយបរទេស ។
- ធ្វើពិព័រណ៍ជាតិ និងអន្តរជាតិ ។
- ទាក់ទងជាមួយបរទេស និងអង្គការអន្តរជាតិ ។
- រៀបចំឯកសារ សំរាប់ថ្នាក់ដឹកនាំប្រជុំជាមួយអន្តរជាតិ ។
- រៀបចំបន្ទាត់នយោបាយ និងយុទ្ធវិធីពាណិជ្ជកម្មក្រៅប្រទេស ។
- ធ្វើសន្ទស្សន៍សេដ្ឋកិច្ច ។

មាត្រា ១៤ .- នាយកដ្ឋាន កម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ ទទួលបន្ទុក :

- ត្រួតពិនិត្យ និងបង្ក្រាបការក្លែងបន្លំគុណភាពទំនិញ ក្នុងតំណាក់កាលចរាចរនៅលើទីផ្សារ ។
- វិភាគគុណភាពទំនិញហូបចុក និងប្រើប្រាស់ ។
- ត្រួតពិនិត្យ និងបញ្ជាក់អំពីភាពសមស្របតាមស្តង់ដាជាតិនូវគុណភាព សុវត្ថិភាព និងផ្លាកសញ្ញានៃម្ហូបអាហារ និងទំនិញប្រើប្រាស់ លើកលែងតែផលិតផលឱសថ បរិក្ខារពេទ្យ និងគ្រឿងសំអាង ។
- ត្រួតពិនិត្យទំនិញនាំចេញ នាំចូល ។

មាត្រា ១៥ .- នាយកដ្ឋាននីតិកម្ម ទទួលបន្ទុក :

-តាក់តែងច្បាប់ពាណិជ្ជកម្ម ។

-កាន់កាប់បញ្ជីពាណិជ្ជកម្ម និង គ្រប់គ្រងសមត្ថភាពពាណិជ្ជកម្មដូចមានចែងក្នុងច្បាប់ ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ។

-ស្រាវជ្រាវ ដកស្រង់ ចងក្រង អត្ថបទច្បាប់ពាណិជ្ជកម្ម និងសន្ធិសញ្ញាវិស័យពាណិជ្ជកម្ម និងគ្រប់គ្រងអត្ថបទច្បាប់ទាំងនោះ ។

-ណែនាំ តាមដានការអនុវត្តន៍ច្បាប់ពាណិជ្ជកម្ម និងសន្ធិសញ្ញាវិស័យពាណិជ្ជកម្ម ។

-ជាទីប្រឹក្សាច្បាប់ពាណិជ្ជកម្មដល់ថ្នាក់ដឹកនាំក្រសួង និងបណ្តាអង្គភាព ក្រុមហ៊ុនអាជីវកម្ម ពាណិជ្ជកម្ម ។

-ចូលរួមបណ្តុះបណ្តាលបំពាក់បំប៉នមន្ត្រីនីតិកម្ម របស់ក្រសួងពាណិជ្ជកម្ម ។

មាត្រា ១៦ .- នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ទទួលបន្ទុក :

-ផ្សព្វផ្សាយពត៌មាន ស្តីពីប្រព័ន្ធអនុគ្រោះទូទៅ (GSP) ដល់ពាណិជ្ជករ ផលិតករមុខទំនិញនាំចេញទាំងឡាយ និង អោយគេចេះប្រើប្រាស់នូវប្រព័ន្ធនេះ ដើម្បីជាអត្ថប្រយោជន៍ដល់ការជំរុញអាហរណកម្មទំនិញពីព្រះរាជាណាចក្រកម្ពុជា ។

-ពិនិត្យ និងចេញវិញ្ញាបនប័ត្រប្រភពដើមទំនិញអោយដល់ផលិតករ អ្នកវិនិយោគទុនទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៧ .- នាយកដ្ឋានកម្មសិទ្ធិបញ្ញា ទទួលបន្ទុក :

-ចងក្រងច្បាប់ និងបទបញ្ញត្តិដែលទាក់ទងដល់ពាណិជ្ជកម្មសញ្ញា ។

-រៀបចំឯកសារសំរាប់ថ្នាក់ដឹកនាំទៅប្រជុំនៅ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ។

-ធ្វើព្រឹត្តិប័ត្រពាណិជ្ជសញ្ញា ។

-រៀបចំបទបញ្ញត្តិ និង បែបបទស្តីពីការចុះបញ្ជីពាណិជ្ជ និង កាន់កាប់បញ្ជីពាណិជ្ជសញ្ញា ។

មាត្រា ១៨ : នាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ ទទួលបន្ទុក :

-វិភាគ និងគ្រប់គ្រងការងារអាស៊ាន ដែលទាក់ទិនផ្ទាល់នឹងសមត្ថកិច្ច របស់ក្រសួងពាណិជ្ជកម្ម ។

- ធ្វើការសំរបសំរួល និងទំនាក់ទំនងជាមួយស្ថាប័ននានា ពិសេសជាមួយអគ្គនាយកដ្ឋានអាស៊ាន របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងអង្គការតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- រួមចំណែករៀបចំមុខទំនិញសំរាប់បញ្ចូលក្នុងកម្មវិធីពន្ធគយអនុគ្រោះ រួម (CEPT Scheme) សំរាប់ AFTA ។
- ចូលរួមរៀបចំគោលនយោបាយ និងយុទ្ធវិធីរបស់កម្ពុជា ក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ាន ។
- ធ្វើជាមជ្ឈមណ្ឌល នៃក្រុមការងារសំរបសំរួល ផ្នែកសេវាកម្មរបស់អាស៊ាន ។
- ធ្វើការចរចាផ្នែកពាណិជ្ជកម្ម តាមកិច្ចព្រមព្រៀងជាទូទៅ ស្តីពីពន្ធគយនឹងពាណិជ្ជកម្ម (GATT) និងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ។
- សហប្រតិបត្តិការផ្នែកពាណិជ្ជកម្ម ជាមួយអង្គការអន្តរជាតិនានាដូចជា : APEC-ESCAP-WIPO-EU-UNCTAD-UNCED ។ល។
- ធ្វើការពិចារណា និងលើកផែនការជូនក្រសួង ដើម្បីទប់ទល់នឹងការធ្វើពាណិជ្ជកម្មមិនសមស្របតាមបទបញ្ញត្តិ អង្គការពាណិជ្ជកម្មពិភពលោក របស់ដៃគូពាណិជ្ជកម្ម ។
- ធ្វើការចរចាលើវិធានការនានាអំពីតារាងពន្ធ និងតារាងមិនមែនពន្ធ (Tariff and Non-Tariffmeasures) ។
- ធ្វើជាអ្នកសម្របសម្រួល អោយក្រសួងពាក់ព័ន្ធ ក្នុងការចរចាជាមួយអង្គការពាណិជ្ជកម្មពិភពលោកក៏ដូចជាដោះស្រាយជំលោះពាណិជ្ជកម្មនានា ។
- ប្រមូលពត៌មានផ្នែកពាណិជ្ជកម្ម ។
- ផ្សព្វផ្សាយបទបញ្ញត្តិ និងកិច្ចព្រមព្រៀងដែលកម្ពុជាត្រូវអនុវត្ត ។

មាត្រា ១៩._ នាយកដ្ឋានជំរុញការនាំចេញ ទទួលបន្ទុក :

- រៀបចំគំរោង និងដឹកនាំផែនការប្រតិបត្តិ ដើម្បីជំរុញលើកកំពស់ពង្រីកនិងបង្កើនសមត្ថភាពដល់ការនាំចេញនូវសំភារៈព្រមទាំងសេវាកម្ម និងពិភាក្សាយ៉ាងជិតស្និតជាមួយផលិតករដែលពាក់ព័ន្ធក្នុងការនាំចេញ ។

- ស្នើឡើងដល់បណ្តាក្រសួងដែលពាក់ព័ន្ធ នូវវិធានការទទួលខុសត្រូវក្នុងការជំរុញ និងបង្កលក្ខណៈងាយស្រួលដល់ការនាំចេញ ផលិតផលក្នុងស្រុក ។
- តំរែតំរង់ និងលើកទឹកចិត្តការចូលរួមរបស់ផលិតករជាតិ នៅក្នុងពិធីតាំងបង្ហាញទំនិញ និងពិព័រណ៍ជាតិព្រមទាំងអន្តរជាតិ ។
- ចូលរួមនៅក្នុងការបង្កើតឡើងនូវបែបបទធ្វើហិរញ្ញប្បទាន និងកិច្ចធានាដល់ការនាំចេញ ។
- ជួយដល់អ្នកនាំចេញក្នុងការស្វែងរកទីផ្សារក្រៅប្រទេស និងសហការដល់រាល់កិច្ចការជំរុញការនាំចេញ ។
- ផ្តល់ពតិមាន និងរៀបចំឯកសារដែលទាក់ទងទៅនឹងការពង្រីក ខាងវិស័យពាណិជ្ជកម្ម និងឈានទៅដល់ការវិភាគ និងផ្សាយចេញនូវពតិមានទាំងនេះផង ។

ជំពូក ៧

អង្គភាពមូលដ្ឋាន

មាត្រា ២០ .- នៅតាមបណ្តា ខេត្ត_ក្រុង និងរាជធានី មានមន្ទីរពាណិជ្ជកម្ម ខេត្ត_ក្រុង និងរាជធានីភ្នំពេញមួយ ដែលទទួលបន្ទុកអនុវត្តការគ្រប់គ្រង វិស័យពាណិជ្ជកម្មនៅមូលដ្ឋាន និងសំរបសំរួលសកម្មភាពរបស់ក្រសួង ។

ជំពូក ៨

សហគ្រាសសាធារណៈ

មាត្រា ២១.- អង្គភាពស្ថិតនៅចំណុច (III) នៃមាត្រា៤ ជាសហគ្រាសសាធារណៈ ជានីតិបុគ្គលដែលទទួលបន្ទុកធ្វើការងារតាមជំនាញឯកទេសរបស់ខ្លួន ស្របតាមច្បាប់លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។ ការរៀបចំ និងការប្រព្រឹត្តិទៅនៃសហគ្រាសសាធារណៈទាំងនោះ ត្រូវគាត់តែងដោយអនុក្រឹត្យ ។

ជំពូក ៩

អង្គភាពត្រួតពិនិត្យ ហិរញ្ញវត្ថុ

មាត្រា ២២.- អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមល័ក្ខខ័ណ្ឌ នៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦

ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្នុងបណ្ដាក្រសួង ។

ជំពូក ១០

អវសាន បញ្ញត្តិ

មាត្រា ២៣._ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលកណ្ដាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

មាត្រា ២៤ ._ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២៥._ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីនិងរដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ២៦._ អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ហត្ថលេខា និងត្រា	ហត្ថលេខានិងត្រា
អ៊ុង ហួត	**ហ៊ុន សែន**

* * *

អង្គការលេខ ក្រសួងពាណិជ្ជកម្ម



អនុក្រឹត្យ លេខ ៥៥ អនក្រ.បក
ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ
របស់ក្រសួងផែនការ

* * * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជា ណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ-កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយក មន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបា កម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩ ស្តីពីការរៀបចំប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ១៩ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ១៩៩៧ ស្តីពី ការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីនាសម័យប្រជុំថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៧

សំរេច

ជំពូក ១

បទបញ្ញត្តិទូទៅ

មាត្រា ១.- អនុក្រឹត្យនេះរៀបចំអង្គភាពនានារបស់ក្រសួងផែនការ និង កំណត់បេសកកម្មរបស់ក្រសួង និង មុខការនៃបណ្ដាអគ្គនាយកដ្ឋាន និង នាយកដ្ឋាននានា ។

ជំពូក ២

បេសកកម្ម និង រចនាសម្ព័ន្ធ

មាត្រា ២.- ក្រសួងផែនការត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់អោយទទួលបន្ទុកបេសកកម្មដឹកនាំ និងគ្រប់គ្រង លើវិស័យផែនការស្ដីពីការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើការ អនុវត្តន៍ ស្ថិតិនៃព្រះរាជាណាចក្រ កម្ពុជា ។

មាត្រា ៣.- ក្រសួងផែនការមានមុខងារនិងភារកិច្ចដូចតទៅ :

- ធ្វើសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំ ទស្សនាទាន យុទ្ធសាស្រ្ត គោលនយោបាយ និងកំណត់អាទិភាពសំរាប់ការអភិវឌ្ឍន៍ប្រទេសជាតិ ដោយឈរលើមូលដ្ឋាននៃការបង្កើតអោយមាននិរន្តភាព និងតុល្យភាពរវាងកិច្ចអភិវឌ្ឍន៍ និងសមភាពយុត្តិធម៌ក្នុងសង្គមរវាងកិច្ចអភិវឌ្ឍន៍ខាងសេដ្ឋកិច្ច និង កិច្ចអភិវឌ្ឍន៍ខាងសង្គមកិច្ច និងវប្បធម៌ រវាងទីក្រុងនិងជនបទ រវាងការធ្វើអាជីវកម្មនិងការកកើតឡើងវិញ នៃធនធានធម្មជាតិនិងការរវាងកិច្ចអភិវឌ្ឍន៍និង ការការពារបរិស្ថាន ។
- ដឹកនាំនិងគ្រប់គ្រងវិធីសាស្រ្ត និងបែបបទក្នុងការរៀបចំផែនការ ស្ដីពីការអភិវឌ្ឍន៍សេដ្ឋសេកិច្ច សង្គមកិច្ច តាមប្រព័ន្ធវិមជ្ឈការក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។
- រៀបចំផែនការ និងកម្មវិធីជាតិសំរាប់កិច្ចអភិវឌ្ឍន៍រយៈពេលវែង មធ្យម និងរយៈពេលខ្លីដោយសំរបសំរួល ជាមួយបណ្ដាក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ដើម្បីអោយផែនការ និង កម្មវិធីជាតិទាំងនោះស៊ីសង្វាក់គ្នារវាងបណ្ដាផ្នែក និង សាខាសេដ្ឋកិច្ច សង្គមកិច្ច ព្រមទាំងខេត្តក្រុង និងតំបន់នានាក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។

- តាមដានត្រួតពិនិត្យ ការអនុវត្តន៍ផែនការ កម្មវិធីជាតិនិងបណ្ដាគំរោងពីគ្រប់ផ្នែក ទាំងអស់ ហើយវាយតំលៃលទ្ធផលនៃការអនុវត្តន៍ និងលើកឡើងពីវិធានការកែតំរូវផែនការកម្មវិធីជាតិទាំងនោះក្នុងករណីចាំបាច់ ។
- រួមជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំយុទ្ធសាស្ត្រ គោលនយោបាយនិងកំណត់អាទិភាពក្នុងការវិនិយោគទាំងឯកជននិងសាធារណៈ ដើម្បីប្រើប្រាស់អោយអស់លទ្ធភាព និងមានប្រសិទ្ធភាពនូវសក្ដានុពលនៃប្រភពធនធានទាំងក្នុង និងក្រៅប្រទេស ។
- សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីកំណត់និងបែងចែកទុនវិនិយោគសាធារណៈប្រចាំឆ្នាំ ។
- រួមជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំយុទ្ធសាស្ត្រគោលនយោបាយ និងកំណត់អាទិភាពក្នុងផែនការសហប្រតិបត្តិការសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌និងវិទ្យាសាស្ត្របច្ចេកទេសជាមួយបរទេសអោយស៊ីសង្វាក់គ្នាជាមួយនឹងទិសដៅ និងគោលនយោបាយអភិវឌ្ឍន៍ជាតិ ។
- រួមជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំគោលនយោបាយ ប្រជាសាស្ត្រ និង ផែនការសកម្មភាព ស្ដីពីការបែងចែកកំលាំងពលកម្មសង្គមអោយមានតុល្យភាព ធានាដល់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនិងការការពារជាតិ ។
- ធ្វើការអង្កេត និងការសិក្សាស្រាវជ្រាវដែលចាំបាច់ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ។
- គ្រប់គ្រងពត៌មានស្ថិតិសេដ្ឋកិច្ច សង្គមកិច្ច និងប្រជាសាស្ត្រក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។
- គ្រប់គ្រងប្រព័ន្ធស្ថិតិជាតិកម្ពុជាតាមការចងក្រង ណែនាំអនុវត្តវិធីប្រើចំណាត់ថ្នាក់ស្ថិតិនិងគំរូតារាងឯកភាពក្នុងការបំពេញនិងការប្រមូលយកពត៌មានស្ថិតិ ណែនាំអនុវត្តវិធីសាស្ត្រនិងរូបមន្តគណនាទិន្នន័យស្ថិតិឯកភាពក្នុងទូទាំងប្រទេស ។
- រៀបចំវិធីសាស្ត្រធ្វើជំរឿន ធ្វើអង្កេត និងអនុវត្តការធ្វើជំរឿន ការធ្វើអង្កេតប្រជារាស្ត្រសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ។

- ផ្តល់ជំនួយខាងផ្នែកបច្ចេកទេសនិងវិធីសាស្ត្រ ឬអនុវត្តការធ្វើជំរឿននិងអង្កេតក្នុងវិស័យនិងប្រធានបទនានាតាមសំណូមពររបស់អ្នកប្រើប្រាស់ទិន្នន័យស្ថិតិ ។
- ចងក្រងគណនេយ្យជាតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវាកម្ម និងកម្រងតួលេខស្ថិតិរបស់កម្ពុជាទៀងទាត់ជាប្រចាំ ។
- សហការដោះដូរពត៌មានស្ថិតិ ជាមួយអង្គភាពស្ថិតិជាតិនៃប្រទេសក្នុងតំបន់ ក្នុងពិភពលោក និងបណ្តាអង្គការជាតិ អង្គការអន្តរជាតិ ។
- បំពេញមុខងារ និងភារកិច្ចចាំបាច់ផ្សេងទៀតតាមការទុកចិត្ត និង ការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ។

មាត្រា ៤ .-ក្រសួងផែនការមានរចនាសម្ព័ន្ធដូចតទៅ :

ក. នៅថ្នាក់កណ្តាល

- អគ្គនាយកដ្ឋានផែនការរួមមាន :
  - +នាយកដ្ឋានផែនការទូទៅ
  - +នាយកដ្ឋានផែនការសេដ្ឋកិច្ច
  - +នាយកដ្ឋានផែនការសង្គមកិច្ច
  - +នាយកដ្ឋានផែនការវិនិយោគ
  - +នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ
- វិទ្យាស្ថានជាតិស្ថិតិដែលមានឋានានុក្រមស្មើថ្នាក់អគ្គនាយកដ្ឋានរួមមាន :
  - +នាយកដ្ឋានស្ថិតិទូទៅ
  - +នាយកដ្ឋានស្ថិតិសេដ្ឋកិច្ច
  - +នាយកដ្ឋានស្ថិតិសង្គមកិច្ច
  - +នាយកដ្ឋានប្រជាសាស្ត្រ ជំរឿន និងអង្កេត
- អគ្គាធិការដ្ឋាន
- ខុទ្ទកាល័យរដ្ឋមន្ត្រី
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានរដ្ឋបាលទូទៅ
- នាយកដ្ឋានផ្គត់ផ្គង់ និង ហិរញ្ញវត្ថុ

ខ– អង្គភាពមូលដ្ឋាន

មន្ទីរផែនការខេត្ត ក្រុង

អង្គការលេខរបស់ក្រសួងផែនការជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

ជំពូក ៣

អគ្គនាយកដ្ឋានផែនការ

មាត្រា ៥.–អគ្គនាយកដ្ឋានផែនការមានមុខងារអនុវត្តនូវរាល់បេសកកម្មរបស់ក្រសួងក្នុងការ :

– ធានាភាពស៊ីសង្វាក់គ្នាក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ដោយសំរបសំរួលផែនការ កម្មវិធីនិងគំរោងអភិវឌ្ឍន៍តាមផ្នែកនិងសាខាសេដ្ឋកិច្ច ដែលរៀបចំឡើងដោយបណ្ដាក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នដែលពាក់ព័ន្ធ និងខេត្ត–ក្រុង ។

– តាមដានត្រួតពិនិត្យការអនុវត្តន៍ផែនការនិង កម្មវិធីជាតិដោយសហការជាមួយក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នដែលពាក់ព័ន្ធ និងខេត្ត ក្រុង ហើយធ្វើរបាយការណ៍បូកសរុបនិងលើកយោបល់ជូនរដ្ឋមន្ត្រី ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាលពិនិត្យ សំរេច ។

– រៀបចំរបាយការណ៍ស្ដីពីសភាពការណ៍សេដ្ឋកិច្ច សង្គមកិច្ច ប្រចាំត្រីមាសទី ១ ឆមាសទី១ ៩ខែដើមឆ្នាំ និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដោយសំរបសំរួលជាមួយ ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នដែលពាក់ព័ន្ធ ខេត្ត ក្រុង និង វិទ្យាស្ថានជាតិស្ថិតិ ។

អគ្គនាយកដ្ឋានផែនការត្រូវដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានផែនការមាននាយកដ្ឋានចំណុះចំនួន ៥ ដូចខាងក្រោម ហើយនាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូបនិងអមដោយ អនុប្រធានមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

មាត្រា ៦.–នាយកដ្ឋានផែនការទូទៅទទួលបន្ទុក :

–កសាងទស្សនាទាន យុទ្ធសាស្ត្រ ផែនការនិងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចជាតិរយៈពេលខ្លី មធ្យម និង រយៈពេលវែង ដោយសំរបសំរួលជាមួយនាយកដ្ឋាននានាចំណុះអគ្គនាយកដ្ឋានផែនការ ។

–វិភាគនិងព្យាករណ៍ពីស្ថានភាពរួមនៃការវិវត្តន៍ ខាងផ្នែកម៉ាក្រូសេដ្ឋកិច្ចនៅក្នុងប្រទេស

ព្រមទាំងលើកឡើងនូវយោបល់និងវិធានការចាំបាច់ដើម្បីកែតំរង់ទិសដៅ នៃការអភិវឌ្ឍន៍ប្រទេសអោយបានទាន់ពេលវេលា ។

–រៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការក្នុងវិស័យម៉ាក្រូសេដ្ឋកិច្ចរួមមានគណនេយ្យជាតិ សារពើពន្ធ ជញ្ជីងទូទាត់ រូបិយវត្ថុ និង ស្ថាប័នហិរញ្ញវត្ថុ ។

មាត្រា ៧.–នាយកដ្ឋានផែនការសេដ្ឋកិច្ចទទួលបន្ទុក :

– វិភាគនិងព្យាករណ៍អំពីស្ថានភាពរួមនៃការវិវត្តន៍ខាងផ្នែកសេដ្ឋកិច្ចនានានៅ ក្នុងប្រទេសព្រមទាំងលើកឡើងនូវយោបល់និងវិធានការចាំបាច់ដើម្បីកែតំរង់ទិដៅនៃការអភិវឌ្ឍន៍ប្រទេស អោយបានទាន់ពេលវេលា ។

– រៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការក្នុងវិស័យសេដ្ឋកិច្ចនានារួមមានជាអាទិ៍ កសិកម្ម រុក្ខកម្ម នេសាទ ឧស្សាហកម្ម គមនាគមន៍ ដឹកជញ្ជូនពាណិជ្ជកម្ម ទេសចរណ៍ សំណង់ និងបរិ ស្ថាន ។

មាត្រា ៨.–នាយកដ្ឋានផែនការសង្គមកិច្ចទទួលបន្ទុក :

–វិភាគនិងព្យាករណ៍អំពីស្ថានភាពរួមនៃការវិវត្តន៍ខាងផ្នែកសង្គមកិច្ចនិងស្ថានភាពប្រជាសាស្ត្រនៅក្នុងប្រទេស ព្រមទាំងលើកឡើងនូវយោបល់និងវិធានការចាំបាច់ដើម្បីកែតំរង់ទិដៅនៃការអភិវឌ្ឍន៍ប្រទេសអោយបានទាន់ពេលវេលា ។

–រៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការក្នុងវិស័យសង្គមកិច្ចរួមមានការងារប្រជាសាស្ត្រ អប់រំ បណ្តុះបណ្តាល អភិវឌ្ឍន៍ធនធានមនុស្ស អភិវឌ្ឍន៍សហគមន៍ ការកាត់បន្ថយភាពក្រីក្រ ផ្ទះសំបែង សុខាភិបាល អាហារូបត្ថម្ភ សង្គមកិច្ច ការងារ វប្បធម៌ តួនាទីបុរសស្ត្រី សាសនា និងពត៌មាន ។

មាត្រា ៩.–នាយកដ្ឋានផែនការវិនិយោគទទួលបន្ទុក :

–វិភាគនិងព្យាករណ៍អំពីស្ថានភាពរួមនៃការអភិវឌ្ឍន៍ខាងផ្នែកវិនិយោគនៅក្នុងប្រទេសទាំងវិនិយោគសាធារណៈនិងឯកជន ព្រមទាំងលើកឡើងនូវយោបល់ និងវិធានការចាំបាច់ ដើម្បីតំរង់ទិសវិនិយោគអោយសមស្របតាមទិសដៅនៃការអភិវឌ្ឍន៍ប្រទេស។

–រៀបចំយុទ្ធសាស្ត្រវិនិយោគរយៈពេលខ្លី មធ្យម និងវែង ។

–កំណត់អាទិភាពក្នុងការបែងចែកទុនតាមវិស័យ ។

–ពិនិត្យសេចក្តីព្រាងគំរោងវិនិយោគសាធារណៈរបស់បណ្តាក្រសួង និងស្ថាប័ននានា។

-រៀបចំកម្មវិធីវិនិយោគសាធារណៈប្រចាំឆ្នាំ ។

-ចូលរួមក្នុងគណៈកម្មការដេញថ្លៃលើគ្រប់គំរោងការងារវិនិយោគសាធារណៈ ។

-តាមដាននិងវាយតំលៃលទ្ធផលនៃការអនុវត្តន៍កម្មវិធីវិនិយោគសាធារណៈ ។

មាត្រា ១០.-នាយកដ្ឋានទំនាក់ទំនងអន្តរជាតិទទួលបន្ទុក :

- វិភាគនិងព្យាករណ៍ពីស្ថានភាពរួម នៃការងារសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយបរទេ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ព្រមទាំងលើកឡើងនូវយោបល់ វិធានការចាំបាច់ ដើម្បីតំរង់ទិសការងារសហប្រតិបត្តិការសេដ្ឋកិច្ច សង្គមកិច្ច វប្បធ និង វិទ្យាសាស្ត្របច្ចេកទេសជាមួយបរទេសអោយស្របតាមទិសដៅ នៃការអភិវឌ្ឍ ប្រទេស ។
- ធ្វើសហប្រតិបត្តិការផ្លាស់ប្តូរពត៌មាន និង សំរបសំរួលក្នុងក្របខ័ណ្ឌការងារផែន អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចជាមួយបរទេសតាមការចាំបាច់ ។
- សំរបសំរួលការងារសហប្រតិបត្តិការសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ វិទ្យាសា បច្ចេកទេសជាមួយបរទេសផ្សេងទៀតតាមការចាំបាច់ និងតាមការប្រគល់ភារកិច្ចពី រដ្ឋាភិបាល ជាអាទិ៍ដូចជា ការងារក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវា បណ្តាប្រទេសក្នុងអនុតំបន់វិសាលភាពទន្លេមេគង្គ (GMS) ជាដើម ។

ជំពូក ៤

វិទ្យាស្ថានជាតិស្ថិតិ

មាត្រា ១១.-វិទ្យាស្ថានជាតិស្ថិតិមានមុខងារអនុវត្តរាល់បេសកកម្មរបស់ក្រសួងក្នុងការធ្វើជំរឿន អង្កេ អំពីសេដ្ឋកិច្ច សង្គមកិច្ចនិងប្រជាសាស្ត្រ ។ ចងក្រងនិងណែនាំវិធីប្រើប្រាស់ចំណា ថ្នាក់ស្ថិតិតារាងឯកភាព និង វិធីសាស្ត្រគណនាទិន្នន័យស្ថិតិប្រមែប្រមូលចងក្រង និ ផ្សព្វផ្សាយទិន្នន័យស្ថិតិស្តីពីស្ថានភាពនៃការវិវត្តន៍ក្នុងផ្នែកសេដ្ឋកិច្ច សង្គមកិច្ចនៅក្ ប្រទេស ។ សហការជាមួយអង្គភាពស្ថិតិជាតិនៃប្រទេសនានាក្នុងតំបន់ និងពិភពលោ ក្នុងការដោះដូរពត៌មានស្ថិតិ បណ្តុះបណ្តាលមន្ត្រីជំនាញការងារស្ថិតិដើម្បីការអភិវឌ្ឍ ប្រព័ន្ធស្ថិតិជាតិកម្ពុជា ។ វិទ្យាស្ថានជាតិស្ថិតិត្រូវដឹកនាំដោយនាយកមួយរូប ដែលតែ តាំងដោយព្រះរាជក្រឹត្យ និងនាយករងមួយចំនួនជួយធ្វើការតាមការចាំបាច់។ វិទ្យាស្ ជាតិស្ថិតិមាននាយកដ្ឋានចំណុះចំនួន ៤ ដូចខាងក្រោម ហើយនាយកដ្ឋាននីមួយ

ដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

មាត្រា ១២.- នាយកដ្ឋានស្ថិតិទូទៅទទួលបន្ទុក :

- សំរបសំរួលទិន្នន័យស្ថិតិជាមួយនាយកដ្ឋាននានាចំណុះវិទ្យាស្ថានជាតិស្ថិតិ ដើម្បីចងក្រងចេញនូវគណនេយ្យជាតិរបស់កម្ពុជា ។
- ប្រមូលយកពត៌មានអំពីថ្លៃទំនិញប្រើប្រាស់និងសេវាកម្ម តាមកាលកំណត់ និងចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្ម ប្រចាំខែ ត្រីមាស ឆមាស ៩ខែដើមឆ្នាំ និងប្រចាំឆ្នាំរបស់កម្ពុជា ។
- ចងក្រង ផ្សព្វផ្សាយ និងណែនាំអនុវត្តដោយឯកភាពនូវចំណាត់ថ្នាក់ ពត៌មានស្ថិតិបណ្តាតារាងគំរូ ប្រមូលយកពត៌មានស្ថិតិពីអង្គភាពរដ្ឋ ឯកជន គ្រឹះស្ថានសាធារណៈនានាសំរាប់ចងក្រងទិន្នន័យស្ថិតិជាតិ ។

មាត្រា ១៣.- នាយកដ្ឋានស្ថិតិសេដ្ឋកិច្ចទទួលបន្ទុក :

- ប្រមូល ចងក្រងពត៌មានបឋមស្តីពីស្ថិតិកសិកម្ម រុក្ខកម្ម នេសាទ ស្ថិតិឧស្សាហកម្ម ពាណិជ្ជកម្ម ស្ថិតិសំណង់ ស្ថិតិគមនាគមន៍ ដឹកជញ្ជូន ស្ថិតិទេសចរណ៍ និងស្ថិតិបរិស្ថាន ។
- សិក្សា និងសហការជាមួយអង្គភាពពាក់ព័ន្ធ រៀបចំនិងធ្វើជំរឿន អង្កេត ប្រមូល ចងក្រងនិងវិភាគពត៌មានស្ថិតិកសិកម្ម រុក្ខកម្ម នេសាទ ស្ថិតិឧស្សាហកម្ម ពាណិជ្ជកម្ម ស្ថិតិសំណង់ ស្ថិតិគមនាគមន៍ ដឹកជញ្ជូន ស្ថិតិទេសចរណ៍ និងស្ថិតិបរិស្ថាន ។

មាត្រា ១៤.- នាយកដ្ឋានស្ថិតិសង្គមកិច្ចទទួលបន្ទុក :

- ប្រមូល ចងក្រងពត៌មានបឋមស្តីពីស្ថិតិសង្គមកិច្ច ការងារ ស្ថិតិអប់រំសិក្សា ស្ថិតិសុខាភិបាល ស្ថិតិពត៌មាន និងស្ថិតិវប្បធម៌ ។
- សិក្សា និងសហការជាមួយអង្គភាពពាក់ព័ន្ធ រៀបចំនិងធ្វើជំរឿន អង្កេតប្រមូល ចងក្រងនិងវិភាគពត៌មានស្ថិតិសង្គមកិច្ច ការងារ ស្ថិតិអប់រំសិក្សា ស្ថិតិសុខាភិបាល ស្ថិតិពត៌មាននិង ស្ថិតិវប្បធម៌ ។

មាត្រា ១៥.- នាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន អង្កេត ទទួលបន្ទុក :

- ធ្វើជំរឿន អង្កេត ប្រមូល ចងក្រង និងគ្រប់គ្រងស្ថិតិប្រជាសាស្ត្រ ។

- សហការធ្វើការរៀបចំ អនុវត្តការធ្វើជំរឿន អង្កេតតាមប្រធានបទនានាក្នុងសំណូមពររបស់បណ្តាអង្គភាព និងអ្នកប្រើប្រាស់ទិន្នន័យស្ថិតិ ។
- ធ្វើការបណ្តុះបណ្តាលបំពេញសមត្ថភាពជំនាញស្ថិតិ ពីថ្នាក់កណ្តាលរហូតដល់មូលដ្ឋានតាមតំរូវការការងារ ។

ជំពូក ៥

អគ្គាធិការដ្ឋាន

មាត្រា ១៦.– អគ្គាធិការដ្ឋានរបស់ក្រសួងផែនការទទួលបន្ទុក :

- ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងផែនការ ។
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តិទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយនោះនិងពីមធ្យោបាយកែលំអការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនោះ ។
- ប្រតិបត្តិភារកិច្ចតាមកាលដែលរដ្ឋមន្ត្រីបានប្រគល់ការទុកចិត្ត ។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប អមដោយអគ្គាធិការរងមួយ ឬ ច្រើនរូបជួយធ្វើការទៅតាមការចាំបាច់ ។

ជំពូក ៦

ខុទ្ទកាល័យរដ្ឋមន្ត្រី

មាត្រា ១៧.– ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយដែលកំណត់តាម បទបញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ដូចមានយោងក្នុង មូលបទខាងលើស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន។

ជំពូក ៧

ការងាររដ្ឋបាល និង ហិរញ្ញវត្ថុ

មាត្រា ១៨.– នាយកដ្ឋានរដ្ឋបាលទូទៅទទួលបន្ទុក :

- សំរបសំរួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទ ។
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។

- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល ។
- សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង ។
- តំកល់ឯកសារ និងគ្រប់គ្រងបណ្ណាល័យ ។

មាត្រា ១៩.-នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុទទួលបន្ទុក :

- ប្រមូលផ្តុំតំរូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំជួសជុលសំភារៈនិងបរិក្ខារ របស់ក្រសួង ។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និង ធ្វើបញ្ជីសារពើភ័ណ្ឌ
- គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង ។ ព្រមទាំងធ្វើកម្ម វិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់ ។
- ទទួល និងបែងចែកបរិក្ខារជូនដល់បណ្តាលអង្គភាពខេត្ត ក្រុងនានា ។
- កាន់បញ្ជីជាប្រចាំនូវសលាកប័ត្រ និងគណនេយ្យបបាតុ ។
- ពតិមានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។
- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។
- លើកគំរោងថវិកាក្រសួង និងតាមដានរំលឹកពីការប្រតិបត្តិ ។
- ប្រមូលផ្តុំ និងសំរបសំរួលជំពូកថវិកា ។
- តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស ។
- ប្រមូលផ្តុំ និងសំរបសំរួលរាល់ចំណាយរបស់ក្រសួង ។
- គ្រប់គ្រងបន្ទុកគណនីនៃការអនុវត្តន៍លទ្ធកម្មសាធារណៈ ។
- ប្រមូលចំណូលអោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុដែលបានកំណត់ ។

មាត្រា ២០.-នាយកដ្ឋានបុគ្គលិកទទួលបន្ទុក :

ក/ក្នុងវិស័យបុគ្គលិក

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- រៀបចំរាល់លិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព ។
- ធ្វើកម្មវិធីតំណែងឯកទេស និង ធនធានមនុស្សរបស់ក្រសួង ។
- វាយតំលៃតំរូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក ។

- រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្តដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអនុវត្តនយោបាយនោះ ។
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងភាពឯកតិមានប្រតិបត្តិ ។
- គ្រប់គ្រងការងារសង្គមរបស់ក្រសួង ។

ខ/ក្នុងវិស័យបណ្តុះបណ្តាល

មជ្ឈមណ្ឌលបណ្តុះបណ្តាលក្រោមខណ្ឌផែនការ ស្ថិតិ ទទួលបន្ទុក ៈ

- រៀបចំការប្រឡងជ្រើសរើសនិងធ្វើការបណ្តុះបណ្តាលនូវមុខវិជ្ជាជំនាញចាំបាច់ក្នុងវិស័យផែនការនិងស្ថិតិ
- រៀបចំធ្វើក្រឹតការ និងសុក្រឹតការចំពោះមន្ត្រីរាជការរបស់ក្រសួង ។

ជំពូក ៨

អង្គភាពមូលដ្ឋាន

មាត្រា ២១._ នៅតាមខេត្ត ក្រុងនីមួយៗមានមន្ទីរផែនការខេត្ត ក្រុង ទទួលបន្ទុកអនុវត្តនិងសំរបសំរួលសកម្មភាពរបស់ក្រសួង ។

ជំពូក ៩

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា ២២._ អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមលក្ខខណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តា ក្រសួង ។

ជំពូក ១០

អវសានបញ្ញត្តិ

មាត្រា ២៣._ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្ងៃថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងផែនការ ។

មាត្រា ២៤._ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២៥.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ២៦.- អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា ហត្ថលេខា និងត្រា

ញ៉ឹ ហ្វូត **ហ៊ុន សែន**

* * *


រដ្ឋមន្ត្រី
អនុរដ្ឋលេខាធិការ
ខុទ្ទកាល័យទីប្រឹក្សា
អគ្គនាយកដ្ឋានផែនការ
វិទ្យាស្ថានជាតិស្ថិតិ
អគ្គាធិការដ្ឋាន
អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ
នាយកដ្ឋានបុគ្គលិក
នាយកដ្ឋានរដ្ឋបាលទូទៅ
នាយកដ្ឋានផ្គត់ផ្គង់ និង ហិរញ្ញវត្ថុ
នាយកដ្ឋានផែនការទូទៅ
នាយកដ្ឋានផែនការសេដ្ឋកិច្ច
នាយកដ្ឋានផែនការសង្គមកិច្ច
នាយកដ្ឋានវិនិយោគ
នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ
នាយកដ្ឋានស្ថិតិទូទៅ
នាយកដ្ឋានស្ថិតិសេដ្ឋកិច្ច
នាយកដ្ឋានស្ថិតិសង្គមកិច្ច
នាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន និង អង្កេត
មន្ទីរផែនការខេត្ត-ក្រុង

អនុក្រឹត្យលេខ ៥៦ អនក្រ.បក

ស្តីពី

ការរៀបចំ និងការប្រព្រឹត្តទៅរបស់

ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ ន.ស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៧

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.- អនុក្រឹត្យនេះកំណត់ការរៀបចំបណ្តុំអង្គភាពនៃក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន និងកំណត់បេសកកម្មរបស់ថ្នាក់ដឹកនាំនិងមុខការនៃបណ្តាអគ្គនាយកដ្ឋាន និង នាយកដ្ឋាននានា ។

ជំពូកទី ២

បេសកកម្ម និងមុខងារសម្ព័ន្ធ

មាត្រា ២.- ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មអោយដឹកនាំ និងគ្រប់គ្រងវិស័យសង្គមកិច្ច វិស័យការងារ និងវិស័យអតីតយុទ្ធជន នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣.- ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនមានមុខងារ និង ភារកិច្ចដូចតទៅ ៖

ក- ក្នុងវិស័យសង្គមកិច្ច :

- រៀបចំការពារផ្នែកសង្គមកិច្ចសំរាប់ប្រជាពលរដ្ឋម្នាក់ៗ ទល់នឹងហានិភ័យផ្សេងៗ និងធ្វើអោយមានសាមគ្គីធម៌ជាគុណប្រយោជន៍ដល់ប្រភេទជនមួយចំនួន ជាអាទិ៍ កុមារ ស្ត្រីមេម៉ាយ ជនចាស់ជរាគ្មានទីពឹង ជនពិការ កុមារកំព្រា ជនរស់នៅតាមចិញ្ចើមថ្នល់ កុមារ តាមចិញ្ចើមថ្នល់ ស្ត្រីពេស្យា ជនដែលមានមេរោគ HIV ។ ល។

ខ- ក្នុងវិស័យការងារ :

- រៀបចំតាក់តែង និង ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ការងារ សំដៅធានាការកែលំអអនាម័យ សុខភាព សន្តិសុខ និងលក្ខខ័ណ្ឌ ធ្វើការងារនៅក្នុងសហគ្រាស ។
- លើកទឹកចិត្តអោយមានសំវាទសង្គម និងការចរចាជាសមូហភាព ។
- អភិវឌ្ឍន៍នយោបាយមុខរបរ និង ផ្នែកលើនយោបាយបណ្តុះបណ្តាលវិជ្ជាជីវៈជួយដល់កម្មករនិយោជិត ពិសេសអ្នកដែលជួបការលំបាកជាងគេ អោយមាន

មុខរបរ និងជួយដល់សហគ្រាសអោយរកបានហត្ថពលករប្រកបដោយគុណភាពតាមតំរូវការរបស់ខ្លួន និងគ្រប់គ្រងទេសន្តរប្រវេសន៍ពលកម្ម ។

- រៀបចំអោយមានរបបសន្តិសុខសង្គមយ៉ាងសមរម្យ ដើម្បីជាផលប្រយោជន៍ដល់កម្មករ និយោជិត និងគ្រួសារ ។

គ–ក្នុងវិស័យអតីតយុទ្ធជន :

- រៀបចំដាក់អោយដំណើរការ សំរបសំរួលនិងវាយតម្លៃនយោបាយជាតិស្តីពីអតីតយុទ្ធជន ។

មាត្រា ៤.~ ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន មានបរនាសម្ព័ន្ធដូចតទៅ :

- ខុទ្ទកាល័យប្រធានស្ថាប័ន
- អគ្គាធិការដ្ឋាន
- នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
- នាយកដ្ឋានផែនការ និងស្ថិតិ
- នាយកដ្ឋាន ហិរញ្ញវត្ថុ និងផ្គត់ផ្គង់
- អគ្គនាយកដ្ឋាន អតីតយុទ្ធជន និងសង្គមកិច្ច
- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អង្គភាពមូលដ្ឋាន
- គ្រឹះស្ថានសាធារណៈក្រោមអាណាព្យាបាល «បេឡាជាតិខាងសន្តិសុខសង្គម»។

អង្គការលេខរបស់ក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

ជំពូកទី ៣

ខុទ្ទកាល័យរដ្ឋលេខាធិការ

មាត្រា ៥.~ ខុទ្ទកាល័យរដ្ឋលេខាធិការ ទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទបញ្ញត្តិ នៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

ជំពូកទី ៤

អគ្គាធិការដ្ឋាន

មាត្រា ៦.- អគ្គាធិការដ្ឋានរបស់ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជនទទួលបន្ទុក :

-ធ្វើអធិការកិច្ចជាប្រចាំលើគ្រប់អង្គភាពក្រោមឱវាទក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ។

-ធ្វើរបាយការណ៍ជូនរដ្ឋលេខាធិការ ពីការប្រព្រឹត្តិទៅរបស់អង្គភាព ដែលបានធ្វើអធិការកិច្ចហើយនោះ និង ពីមធ្យោបាយកែលំអការប្រព្រឹត្តិទៅ របស់អង្គភាពទាំងនោះ ។

-ប្រតិបត្តិភារកិច្ចតាមកាលដែលរដ្ឋលេខាធិការបានប្រគល់ទុកចិត្ត ។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការម្នាក់ អមដោយអគ្គាធិការរងមួយ ឬច្រើនរូបជួយធ្វើការទៅតាមការចាំបាច់ ។

ជំពូកទី ៥

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

មាត្រា ៧.-នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក មានមុខការដូចតទៅ ÷

ក-ក្នុងវិស័យរដ្ឋបាលទូទៅ :

- សំរបសំរួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទ ។
- គ្រប់គ្រង និងចរាចរ ឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង ។
- សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង ។

ខ-ក្នុងវិស័យគ្រប់គ្រងបុគ្គលិក :

-គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនង ជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

-រៀបចំវាល់លិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព ។

-ធ្វើកម្មវិធីពីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង ។

-វាយតម្លៃតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក ។

–រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និង បន្តដោយទំនាក់ជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង អនុវត្តនយោបាយនោះ ។

–រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពតិមានប្រតិបត្តិ ។

–គ្រប់គ្រងការងារសង្គមរបស់ក្រសួង ។

មាត្រា ៨.– នាយកដ្ឋានផែនការ និងស្ថិតិ ទទួលបន្ទុក :

–សិក្សា រៀបចំទិន្នន័យ និងកំណត់កម្មវិធីសកម្មភាព និងកំណត់គំរោងការ ។

–វាយតំលៃបរិមាណ និងគុណភាពរបស់រដ្ឋបាលសង្គមកិច្ចការងារ និងអតីតយុទ្ធជន ។

–សិក្សាស្ថិតិ និងសិក្សាសំរាប់អនាគតស្តីពីការងារសង្គមកិច្ច និងអតីតយុទ្ធជន ។

មាត្រា ៩.– នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ មានមុខការដូចតទៅ :

ក– ក្នុងវិស័យគ្រប់គ្រងបន្ទុកគណនី និងហិរញ្ញវត្ថុ :

–លើកគំរោងថវិកាក្រសួង និងតាមដានវិលិកពីការប្រតិបត្តិ ។

–ប្រមូលចំណូលអោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ ដែលបានកំណត់ ។

–ប្រមូលផ្តុំ និងសំរបសំរួលជំពូកថវិកា ។

–តាមដានវិលិកការគ្រប់គ្រងគណនីពិសេស ។

–ប្រមូលផ្តុំ និងសំរបសំរួលរាល់ចំណាយរបស់ក្រសួង ។

–គ្រប់គ្រងបន្ទុកគណនី នៃការអនុវត្តន៍លទ្ធកម្មសាធារណៈ ។

ខ– ក្នុងវិស័យផ្គត់ផ្គង់ :

–ប្រមូលផ្តុំតំរូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំផ្គត់ផ្គង់សំភារៈ និងបរិក្ខាររបស់ក្រសួង ។

–គ្រប់គ្រងចលនទ្រព្យអចលនទ្រព្យសន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ ។

–គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋ ដែលប្រគល់អោយក្រសួងព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់ ។

–ទទួល និងបែងចែកបរិក្ខារ ជូនដល់បណ្តាអង្គភាពខេត្ត–ក្រុងនានា ។

–កាន់បញ្ជីជាប្រចាំនូវសលាកបត្រ និងគណនេយ្យរូបធាតុ ។

–ពតិមានវិទ្យាសកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។

–ត្រួតពិនិត្យបច្ចេកទេស នៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។

ជំពូកទី ៦

អគ្គនាយកដ្ឋានអតីតយុទ្ធជន និងសង្គមកិច្ច

មាត្រា ១០.–អគ្គនាយកដ្ឋានអតីតយុទ្ធជន និងសង្គមកិច្ចទទួលបន្ទុកធ្វើទំនាក់ទំនងសំរបសំរួល គ្រប់គ្រងកិច្ចការសោធនអតីតយុទ្ធជន អភិវឌ្ឍន៍អតីតយុទ្ធជន និងវិមានសព និងធ្វើទំនាក់ទំនង សំរបសំរួលគ្រប់គ្រង កិច្ចការសុខុមាលភាពសង្គម សុខុមាលភាពកុមារ និង ស្តារលទ្ធភាព ពលកម្ម ។

អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករងមួយ ឬ ច្រើនរូបជួយធ្វើការទៅតាមការចាំបាច់ ។

អគ្គនាយកដ្ឋានអតីតយុទ្ធជន និងសង្គមកិច្ចមាននាយកដ្ឋាន ៥ គឺ :

ក–នាយកដ្ឋាន សោធនអតីតយុទ្ធជន

ខ–នាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន

គ–នាយកដ្ឋានសុខុមាលភាពសង្គម

ឃ–នាយកដ្ឋានសុខុមាលភាពកុមារ

ង–នាយកដ្ឋានស្តារលទ្ធភាពពលកម្ម ។

មាត្រា ១១.– អគ្គនាយកដ្ឋានសោធនអតីតយុទ្ធជន មានមុខការដូចតទៅ :

–រៀបចំរាល់អត្ថបទច្បាប់ និងបទបញ្ញាទាក់ទងដល់អតីតយុទ្ធជន ។

–សិក្សា និងធ្វើបញ្ញត្តិរបបនយោបាយសំរាប់អតីតយុទ្ធជន ។

–ទូទាត់ប្រាក់ឧបត្ថម្ភជូនអតីតយុទ្ធជន ។

–រក្សាទុក និងគ្រប់គ្រងប័ណ្ណសារអតីតយុទ្ធជន ។

–បង្កើត រៀបចំ និងថែទាំផ្នូរសពអតីតយុទ្ធជន ។

–ចូលរួមក្នុងការរៀបចំទិវាជាតិអតីតយុទ្ធជន ។

–បង្កើត និងលើកតំលៃវិមានសព ។

–សម្របសម្រួលការស្រាវជ្រាវប្រវត្តិសាស្ត្រអតីតយុទ្ធជន ។

មាត្រា ១២.–នាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន មានមុខការដូចតទៅ :

–ជួយដល់អតីតយុទ្ធជនក្នុងការស្វែងរកការងារ និងមុខរបរ ។

-ជួយអភិវឌ្ឍន៍សហគមន៍ ក្នុងគោលដៅធ្វើអោយប្រសើរលក្ខខណ្ឌជីវភាពរស់នៅ របស់អតីតយុទ្ធជន ។

-គ្រប់គ្រងមូលនិធិអតីតយុទ្ធជន ។

មាត្រា ១៣.- នាយកដ្ឋានសុខុមាលភាពសង្គម មានមុខការជំរុញជួយប្រភេទប្រជាជនដែលមានការខ្វះខាតជាងគេ ។ ក្នុងន័យនេះនាយកដ្ឋាននេះមានមុខការដូចតទៅ :

-ជួយដល់ស្ត្រីមេម៉ាយដែលមានស្ថានភាពលំបាក ស្ត្រី ជនកំសត់គ្មានទីពឹង និងជនចាស់ នៅតាមចិញ្ចើមថ្នល់ ។

-ជួយដល់ស្ត្រីពេស្យា ដោយឈរលើមូលដ្ឋាននៃការបង្កើតអត្ថបទច្បាប់ ការត្រួតពិនិត្យ និងរៀបចំផែនការ និងវិធានការសំរាប់ទប់ស្កាត់ការរីករាលដាល នៃពេស្យាចារ ដោយសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ។

-ទទួល និងបែងចែកជំនួយដល់ជនគ្រោះដោយសង្គ្រាម ដោយគ្រោះធម្មជាតិ និងគ្រោះ ថ្នាក់ផ្សេងៗទៀត ដោយសហការជាមួយក្រសួងនានា ។

-គ្រងសោធសំរាប់ការចូលនិវត្ត និងការចូលបាត់បង់សមត្ថភាពពលកម្ម របស់មន្ត្រីរាជការស៊ីវិល និងយោធា ។

-គ្រប់គ្រងប្រាក់ឧបត្ថម្ភដល់កុមារដែលកំព្រាពីសពមន្ត្រីរាជការ ។

មាត្រា ១៤.- នាយកដ្ឋានសុខុមាលភាពកុមារមានមុខការដូចតទៅ :

-ជួយដល់កុមារកំព្រា ដោយថែរក្សាការពារ និងអប់រំគេអោយក្លាយជាពលរដ្ឋល្អក្នុងសង្គម ។

-ការពារកុមារកំព្រាដែលគេបោះបង់ចោល ។

-សង្គ្រោះកុមារដែលត្រូវគេរំលោភបំពានខាងរាងកាយ ជួញដូរ និង ធ្វើអាជីវកម្មខាងផ្លូវភេទ ។

មាត្រា ១៥.- នាយកដ្ឋានស្តារលទ្ធភាពពលកម្ម មានមុខការដូចតទៅ :

-ស្តារលទ្ធភាពពលកម្ម និងសមាហរណកម្ម ជនពិការទូទាំងប្រទេស ។

-ផ្តល់ការព្យាបាលដោយចលនា ។

-បំពាក់អវៈយវៈសិប្បនិម្មិត ។

-អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ជំពូកទី ៦

អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

មាត្រា ១៦.– អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលបន្ទុកធ្វើទំនាក់ទំនងសំរបសំរួលគ្រប់គ្រងកិច្ចការ អធិការកិច្ចការងារ មុខរបរនិងហត្ថពលកម្មពេទ្យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករងមួយឬច្រើនរូប ជួយធ្វើការទៅតាមការចាំបាច់ ។

អគ្គនាយកដ្ឋានការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ មាននាយកដ្ឋាន៥ គឺ :

ក–នាយកដ្ឋានអធិការកិច្ចការងារ

ខ–នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម

គ–នាយកដ្ឋាន និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ឃ–នាយកដ្ឋានពេទ្យការងារ

ង–នាយកដ្ឋានសន្តិសុខសង្គម ។

មាត្រា ១៧.–នាយកដ្ឋាន អធិការកិច្ចការងារ មានបេសកកម្មជំរុញអោយអនុវត្តបទបញ្ញាការងារ។ ក្នុងកិច្ចការនេះ នាយកដ្ឋាននេះមានមុខការដូចតទៅ :

–តាក់តែង និងអនុវត្តន៍ បណ្តាបទបញ្ញត្តិច្បាប់ និងបទបញ្ញាដែលទាក់ទងនឹងល័ក្ខខ័ណ្ឌការងារ និងការការពារ កម្មករ និយោជិត ក្នុងពេលប្រកបវិជ្ជាជីវៈរបស់ខ្លួន ។

–តាក់តែង និងកែលំអ លើកកំពស់បទបញ្ញត្តិច្បាប់ និងបទបញ្ញាដែលទាក់ទងដល់សេរីភាពក្នុងការបង្កើតសហជីព និងការបង្កើតអង្គការតំណាងរបស់កម្មករនិយោជិត និងនិយោជក នៅក្នុងសហគ្រាស ។

–ជំរុញ សម្របសំរួល ក្នុងការចុះធ្វើអធិការកិច្ចការងារតាមសហគ្រាសនិងត្រួតពិនិត្យសកម្មភាពអធិការកិច្ចការងារគឺ ក្នុងន័យឃ្លាំមើលអោយមានការគោរពបទបញ្ញត្តិទាំងអស់នោះក្នុងសហគ្រាស ដោយផ្តល់ជាសេចក្តីជូនដំណឹង ឬ

និវាទ ឬក្នុងករណីចាំបាច់ ជួយទប់ស្កាត់ការរំលោភនានាដែលបានសំគាល់ឃើញ ។

-ជួយការពារដល់បណ្តាអង្គការតំណាងរបស់កម្មករនិយោជិត និងនិយោជកនៅក្នុងសហគ្រាស ។

-ដាក់អោយដំណើរការនូវនីតិវិធីសំរាប់ដោះស្រាយវិវាទការងារ ។

-តាមដាន និងជំរុញការចរចាជាសមូហភាពនិងសំវាទសង្គម ព្រមទាំងពិនិត្យ និងចុះបញ្ជីកាលើអត្ថបទនៃអនុសញ្ញានានា ។

-ទទួលបន្ទុកកិច្ចការលេខាធិការដ្ឋានរបស់គណៈកម្មការប្រឹក្សាការងារ និងរៀបចំរាល់ កិច្ចការរបស់គណៈកម្មការនេះ ។

មាត្រា ១៨.- នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម មានមុខការដូចតទៅ :

-សិក្សា និងលើកវិធានការសំរាប់អភិវឌ្ឍន៍ និងការការពារមុខរបរ ។ រៀបចំក្របខ័ណ្ឌគតិយុត្តិពីវិធានការទាំងនោះ ដាក់អោយអនុវត្តវិធានការ និងតាមដានការអនុវត្តន៍ ។

-រៀបចំអោយមានការិយាល័យរកការអោយធ្វើ ចាត់ចែង និងត្រួតពិនិត្យសេចក្តីត្រូវការចំនួនតម្រូវការការងារ និងពាក្យស្នើសុំការងារធ្វើ ។

-សិក្សាពីតម្រូវការដែលមិនទាន់អាចបំពេញបានរបស់ទីផ្សារការងារដែលទាមទារអោយមានការបណ្តុះបណ្តាល និង ពិសេសមានការជួយរួមចំណែកពីនាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ ។

-កសាងស្ថិតិទីផ្សារការងារ និង ចូលរួមក្នុងការសិក្សាស្ថិតិទាំងនោះ ដោយសហការជាមួយនាយកដ្ឋានផែនការ និងស្ថិតិ ។

-ញាក់ក្តែងបទបញ្ញត្តិ និងបទបញ្ជា ទាក់ទងដល់លក្ខខ័ណ្ឌការងារ នៃកម្មករនិយោជិតបរទេស ដោយពិគ្រោះយោបល់ជាមួយបណ្តានាយកដ្ឋាន ក្នុងក្រសួង ឬ បណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ។ ចេញអោយ និងដកហូត ប័ណ្ណការងារសំរាប់ជនបរទេស ។

-បណ្តានាយកដ្ឋានក្នុងក្រសួង ឬបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ។ ចេញអោយនិងដកហូតប័ណ្ណការងារសំរាប់ជនបរទេស ។

-ចាត់ចែង និងគ្រប់គ្រងការបញ្ជូនពលករកម្ពុជាទៅធ្វើការនៅបរទេស ។

មាត្រា ១៩.- នាយកដ្ឋានពេទ្យការងារមានមុខការដូចតទៅ :

- តាក់តែងអត្ថបទច្បាប់ និងបទបញ្ញាការងារស្តីពីការការពារហានិភ័យវិជ្ជាជីវៈ ជាអាទិ៍សុខភាពកម្មករ និយោជិត ដោយសហការជាមួយនាយកដ្ឋានអធិការកិច្ចការងារ ។
- ទំនាក់ទំនង សហប្រតិបត្តិការជិតស្និទជាមួយនាយកដ្ឋានអធិការកិច្ចការងារ ដើម្បីអនុវត្តន៍ច្បាប់ និងបទបញ្ញាពាក់ព័ន្ធនឹងអនាម័យការងារ និងការការពារសុខភាព កម្មករនិយោជិត ។
- វាយតំលៃ និងត្រួតពិនិត្យជាប្រចាំ នូវសកម្មភាពរបស់អង្គភាពពេទ្យការងារ និង គ្រូពេទ្យ ការងារនៅតាមសហគ្រាស ។
- ជំរុញ សំរបសំរួលនិងត្រួតពិនិត្យសកម្មភាពរបស់អធិការពេទ្យការងារ ដែលជាអ្នកធ្វើសកម្មភាពជាអចិន្ត្រៃយ៍ សំដៅការពារសុខភាពកម្មករនិយោជិតនៅកន្លែងធ្វើការ ។
- ជំរុញ និងគាំទ្រខាងហិរញ្ញវត្ថុចំពោះការសិក្សាមានលក្ខណៈវេជ្ជសាស្ត្រ ពាក់ព័ន្ធដល់សុខភាពក្នុងការងារ ។

មាត្រា ២០.- នាយកដ្ឋានសន្តិសុខសង្គម មានមុខងារដូចតទៅ :

- ធ្វើបញ្ញត្តិ និងដាក់អោយអនុវត្តវិធានការ សំដៅការពារកម្មករនិយោជិត និងគ្រួសារទល់នឹងហានិភ័យសង្គមនានា ដែលអាចនាំអោយបាត់បង់ ឬ បន្ថយលទ្ធផលការងាររបស់ខ្លួន និងសំដៅជួយកម្មករនិយោជិតអោយអាច ទ្រទ្រង់បន្ទុកគ្រួសារបាន ។
- តាក់តែងអត្ថបទពាក់ព័ន្ធនឹងការរ៉ាប់រងដល់កម្មករនិយោជិត ស្តីពីមាតុភាព មរណៈភាព ពិការភាព និងជរាភាព ក៏ដូចជាការរៀបចំបទបញ្ញត្តិ ពាក់ព័ន្ធនឹងការរ៉ាប់រងចំពោះគ្រោះថ្នាក់ការងារ និងជម្ងឺវិជ្ជាជីវៈ ព្រមទាំងបទបញ្ញត្តិដែលគ្រោងពីការផ្តល់តាវកាលិកគ្រួសារ ។
- រ៉ាប់រងការតាមដាន ការអនុវត្តន៍បទបញ្ញត្តិច្បាប់ និងបទបញ្ញាទាំងឡាយ និងជាអាណាព្យាបាលលើអង្គការដែលបានបង្កើតហើយ ដើម្បីធានាការអនុវត្តន៍វិធានការ ទាំងនោះ ។

មាត្រា ២១.–នាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ មានមុខការដូចតទៅ :

–រៀបចំ ជំរុញ និង សំរបសំរួលនយោបាយបណ្តុះបណ្តាលវិជ្ជាជីវៈដល់មនុស្សពេញវ័យ ដោយទំនាក់ទំនងជាមួយក្រសួងអប់រំ និងបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និង បណ្តាដៃគូសង្គមនានា ។

–រៀបចំក្របខ័ណ្ឌគតិយុត្តិនយោបាយនេះ ។

–ដាក់អោយអនុវត្ត និងតាមដានការអនុវត្តន៍វិធានការ និងវាយតម្លៃលទ្ធផលនៃការអនុវត្តន៍ ។

–ទទួលបន្ទុកជាលេខាធិការដ្ឋាននិងចាត់ចែងអោយមានអង្គការពិគ្រោះយោបល់ដែលពាក់ព័ន្ធដល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់មនុស្សពេញវ័យ។

–គ្រប់គ្រងមូលនិធិនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ របស់ក្រសួង ។

–ដោះស្រាយបញ្ហាកំណត់និយមន័យលក្ខន្តិកៈ និងលាភការកម្មសិក្សាការីខាងការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

–ទទួលបន្ទុកបញ្ញាសទិសានុញ្ញាត និងសុពលភាពនៃគីរតវិជ្ជាជីវៈដែលក្រសួងផ្តល់ជូនដោយសហការជាមួយក្រសួងពាក់ព័ន្ធ ។

–រៀបចំអត្ថបទច្បាប់ និងបទបញ្ញាពាក់ព័ន្ធនឹងការហ្វឹកហ្វឺនកូនជាង និងតាមដានការ អនុវត្តន៍ ។ រៀបចំប្រព័ន្ធត្រួតពិនិត្យវិធានការទាំងនោះ ។

ជំពូកទី ៤

អង្គភាពមូលដ្ឋាន

មាត្រា ២២.–នៅតាមខេត្ត–ក្រុងនីមួយៗ មានអធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជនខេត្ត–ក្រុងមួយ ដែលទទួលបន្ទុកអនុវត្តនិងសំរបសំរួលសកម្មភាពរបស់ក្រសួង ។

នៅតាម ខ័ណ្ឌ–ស្រុក មានការិយាល័យសង្គមកិច្ចការងារ និងអតីតយុទ្ធជនមួយ ដែលទទួលបន្ទុកអនុវត្ត និងសំរបសំរួលសកម្មភាពរបស់ក្រសួង ។

ជំពូកទី ៩

គ្រឹះស្ថានសាធារណៈក្រោមអាណាព្យាបាល

មាត្រា ២៣.- បេឡាជាតិខាងសន្តិសុខសង្គម ជាគ្រឹះស្ថានសាធារណៈ មាននីតិបុគ្គល និងស្វ
ស្វ័យភាពហិរញ្ញវត្ថុ ទទួលបន្ទុកគ្រប់គ្រងការការពារសង្គម ចំពោះកម្មករនិយោជិ
ដែលស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ ។

ការរៀបចំ និងការប្រព្រឹត្តិទៅ នៃគ្រឹះស្ថានសាធារណៈនេះ ត្រូវតាក់តែ
ដោយអនុក្រឹត្យមួយដោយឡែក ។

ជំពូកទី ១០

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា ២៤.- អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើង ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិ
និងហិរញ្ញវត្ថុ តាមលក្ខខណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃ
១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើក
ចំណាយថវិកា ក្នុងបណ្តាក្រសួង ។

ជំពូកទី ១១

អវសានប្បញ្ញត្តិ

មាត្រា ២៥.- ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោ
នាយកដ្ឋានចុះ និងថ្នាក់ ខេត្ត-ក្រុង ខណ្ឌ-ស្រុក ត្រូវកំណត់ដោយប្រកាសរប
រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន ។

មាត្រា ២៦.- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២៧.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងសង្គមកិ
ការងារ និង អតីតយុទ្ធជន រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ ដែលមានក
ពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ២៨.- អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
អ៊ឹង ហួត	ហ៊ុន សែន

* * *

អង្គការលេខក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន



អនុក្រឹត្យលេខ ៥៧ អនក្រ.បក

ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការ បង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីនាសម័យប្រជុំថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ១៩៩៧

សំរេច

ជំពូក ១

បទបញ្ញត្តិទូទៅ

មាត្រា ១.-អនុក្រឹត្យនេះរៀបចំបណ្តាអង្គភាព នៃក្រសួងបរិស្ថាន និងកំណត់បេសកកម្មរបស់ក្រសួង និងមុខការ នៃអគ្គនាយកដ្ឋាន និងនាយកដ្ឋាននានា ។

ជំពូក ២

បេសកកម្ម និងរចនាសម្ព័ន្ធ

មាត្រា ២.-ក្រសួងបរិស្ថានត្រូវបានរាជរដ្ឋាភិបាលប្រគល់បេសកកម្មអោយដឹកនាំ និង គ្រប់គ្រងវិស័យបរិស្ថាននៃ ព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣.-ក្រសួងបរិស្ថានមានមុខងារ និងភារកិច្ចដូចតទៅ ៖

- អនុវត្តនយោបាយបរិស្ថាន ដោយផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍន៍ប្រទេសប្រកបដោយនិរន្តភាព និង ភាពស្ថិត ស្ថេរ ព្រមទាំងរៀបចំសំណើស្តីពីផែនការបរិស្ថានជាតិ និងផែនការបរិស្ថានតំបន់ដោយ សហការ ជាមួយក្រសួងពាក់ព័ន្ធ ។
- រៀបចំ និងអនុវត្តបរិធានច្បាប់បរិស្ថាននានា ដើម្បីជំរុញ និង ធានាអោយមានការអភិវឌ្ឍន៍ប្រទេស ប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរ ។
- អង្កេតពិនិត្យ និងផ្តល់យោបល់លើការវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ដែលស្នើឡើង មានស្រាប់ និងកំពុងដំណើរការ ព្រមទាំងរៀបចំសំណើ ស្តីពីបែបបទនៃកិច្ចដំណើរការរៀបចំ និងពិនិត្យឡើងវិញនូវការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។
- ផ្តល់យោបល់ដល់ក្រសួងពាក់ព័ន្ធដើម្បីធានាការអភិរក្ស ការអភិវឌ្ឍន៍ និងការគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិ រួមមាន ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាតនិងឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើ

និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆជាតិ ធនធានជលផល ដោយសមហេតុសមផល ប្រកបដោយនិរន្តរភាពនិងភាពស្ថិតស្ថេរ ។

-គ្រប់គ្រងតំបន់ការពារធម្មជាតិនានា ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ដូចមានចែងនៅក្នុងព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិ ចុះថ្ងៃទី០១ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងលើកសំណើស្តីពីការបង្កើតតំបន់ការពារធម្មជាតិថ្មីៗ បន្ថែមទៀត ។

-ចងក្រងបញ្ជីសារពើភ័ណ្ឌដែលបញ្ជាក់ពីប្រភព ប្រភេទ និងបរិមាណនៃសំណល់រឹង រាវ សាធាតុបំពុល សារធាតុប្រកបដោយគ្រោះថ្នាក់ ផ្សែង សំឡេង និងរំញ័រ ព្រមទាំងដាក់តែងវិធានការទប់ស្កាត់ កាត់បន្ថយ និងត្រួតពិនិត្យការបំពុលបរិស្ថាន ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

-រៀបចំនីតិវិធីនៃការធ្វើអធិការកិច្ចលើប្រភពបំពុល និងការធ្វើរបាយការណ៍ស្តីពីបទល្មើសជូនស្ថាប័នមានសមត្ថកិច្ច ព្រមទាំងសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីអនុវត្តការធ្វើអធិការកិច្ចលើ ប្រភពបំពុល និងធ្វើរបាយការណ៍ស្តីពីបទល្មើសជូនស្ថាប័នមានសមត្ថកិច្ច ។ អនុវត្តការដាក់ពិន័យអន្តរការណ៍ និងបទបញ្ញត្តិនានាដូចមានចែងក្នុងជំពូកទី៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ។

-ប្រមូល វិភាគ និងគ្រប់គ្រងទិន្នន័យបរិស្ថាន និងរៀបចំចងក្រងរបាយការណ៍ប្រចាំឆ្នាំ ស្តីពីស្ថានភាពបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា ។ ផ្តល់ពត៌មានស្តីពីសកម្មភាពរបស់ខ្លួននិងពត៌មាន ដែលទាក់ទងទៅនឹងកិច្ចការពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ឬស្ថានភាពបរិស្ថានជូនសាធារណជន ព្រមទាំងលើកទឹកចិត្តអោយមានការចូលរួមពីសាធារណជនក្នុងកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ។

-ដាក់តែង និង អនុវត្តកម្មវិធីអប់រំបរិស្ថានសំរាប់គ្រប់ស្រទាប់នៃសង្គម ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ ។

-លើកសំណើជូនរាជរដ្ឋាភិបាលលើការចូលរួមក្នុងកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារអន្តរជាតិនានា ស្តីពីកិច្ចការពារបរិស្ថាន ព្រមទាំងបំពេញកិច្ចការជំនាញពាក់

ព័ន្ធសំរាប់ជាមូលដ្ឋានអោយរាជរដ្ឋាភិបាលបំពេញកាតព្វកិច្ច និង ការទទួលខុសត្រូវទាក់ទងនឹងកិច្ចព្រមព្រៀងអនុសញ្ញា និងពិធីសារអន្តរជាតិទាំងនោះ ។

_ជំរុញលើកទឹកចិត្តការវិនិយោគទុនក្នុងវិស័យការពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិ ព្រមទាំងរៀបចំ និង គ្រប់គ្រងមូលនិធិឧបត្ថម្ភទានបរិស្ថានសំរាប់កិច្ចការការពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិ ។

_សហការជាមួយអង្គការជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សហគមន៍មូលដ្ឋាន និងបណ្តាប្រទេសនានា សំដៅធានាកិច្ចការពារបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៤._ក្រសួងបរិស្ថានមានរចនាសម្ព័ន្ធដូចតទៅ ៖

ក_នៅថ្នាក់កណ្តាល :

_ អគ្គនាយកដ្ឋានបច្ចេកទេស :

- នាយកដ្ឋានផែនការ និងកិច្ចការច្បាប់
- នាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ
- នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន
- នាយកដ្ឋានវាយតំលៃធនធានធម្មជាតិ និងគ្រប់គ្រងទិន្នន័យបរិស្ថាន
- នាយកដ្ឋានអប់រំពត៌មាន និងផ្សព្វផ្សាយបរិស្ថាន
- នាយកដ្ឋានអង្កេតពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

_ អធិការដ្ឋាន

_ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

_ ខុទ្ទកាល័យរដ្ឋមន្ត្រី

ខ_អង្គភាពមូលដ្ឋាន :

_មន្ទីរបរិស្ថានខេត្ត_ក្រុង

ជំពូក ៣

អគ្គនាយកដ្ឋានបច្ចេកទេស

មាត្រា ៥._អគ្គនាយកដ្ឋានបច្ចេកទេសទទួលបន្ទុកធ្វើទំនាក់ទំនង សំរបសំរួល គ្រប់គ្រងកិច្ចការផែនការនិងកិច្ចការច្បាប់ ការពារនិងអភិរក្សធម្មជាតិ ត្រួតពិនិត្យការបំពុលបរិស្ថាន វាយតំលៃធនធានធម្មជាតិ និង គ្រប់គ្រងទិន្នន័យបរិស្ថាន អប់រំ ពត៌មាននិងផ្សព្វផ្សាយបរិស្ថាន និងអង្កេតពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។ អគ្គនាយកដ្ឋានបច្ចេកទេសដឹកនាំដោយអគ្គនាយកមួយរូប ដែលអមដោយអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានបច្ចេកទេសមាននាយកដ្ឋានចំណុះចំនួន ៦ ដូចតទៅ ៖

_នាយកដ្ឋានផែនការ និងកិច្ចការច្បាប់

_នាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ

_នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន

_នាយកដ្ឋានវាយតំលៃធនធានធម្មជាតិ និងគ្រប់គ្រងទិន្នន័យបរិស្ថាន

_នាយកដ្ឋានអប់រំ ពត៌មាន និងផ្សព្វផ្សាយបរិដ្ឋាន

_នាយកដ្ឋានអង្កេតពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

មាត្រា ៦._នាយកដ្ឋានផែនការ និងកិច្ចការច្បាប់មានភារកិច្ចសហការជាមួយនាយកដ្ឋាន ជំនាញ ដើម្បី ៖

_រៀបចំពង្រាងបរិធានច្បាប់ សំរាប់អនុវត្តច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

_សហការ ពិនិត្យឡើងវិញ និងផ្តល់យោបល់លើការរៀបចំបរិធានច្បាប់នានាដោយស្ថាប័នផ្សេងៗ ដែលទាក់ទងនឹងបេសកកម្មរបស់ក្រសួង ។

_ផ្តល់យោបល់ទាក់ទងនឹងផ្នែកច្បាប់ជូនថ្នាក់ដឹកនាំក្រសួង និងនាយកដ្ឋានជំនាញ ស្តីពីការអនុវត្តន៍សិទ្ធិអំណាចដែលមានចែងនៅក្នុងច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

_រៀបចំគោលនយោបាយការពារបរិស្ថាន អភិរក្ស និង ប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរ ដោយសហការជាមួយក្រសួងពាក់ព័ន្ធ ។

_រៀបចំផែនការបរិស្ថានជាតិ ផែនការបរិស្ថានតំបន់ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

_រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការការងារ ព្រមទាំងតាមដានវាយតំលៃលទ្ធផលការងាររបស់ក្រសួង ។

_សហការជាមួយនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្នុងការលើកគំរោងថវិកាប្រចាំឆ្នាំរបស់ក្រសួង ការបែងចែកថវិកាទាំងនោះតាមអង្គភាពចំណុះរបស់ក្រសួង និងផ្តល់យោបល់ជូនឯកឧត្តមរដ្ឋមន្ត្រី ។

_សំរបសំរួលសកម្មភាព និងគំរោងជំនួយទ្វេភាគី និងពហុភាគី ដែលផ្តល់អោយក្រសួងបរិស្ថាន ដើម្បីធានាអោយសកម្មភាព និង គំរោងទាំងនោះឆ្លើយតបចំទិសដៅនយោបាយនិងអាទិភាពរបស់ក្រសួង។

_ធ្វើសហប្រតិបត្តិការអន្តរជាតិ។

_សំរបសំរួល និងគ្រប់គ្រងការរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន និង មន្ទីរបរិស្ថានខេត្តទាំងអស់ ។

មាត្រា ៧._នាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ មានភារកិច្ចសហការជាមួយនាយកដ្ឋានជំនាញដើម្បី :

_បំពេញកិច្ចការជំនាញពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារអន្តរជាតិនានាស្តីពីការអភិរក្សធម្មជាតិ និងតំបន់ការពារធម្មជាតិ ។

_រៀបចំ អនុវត្តគោលនយោបាយ និងផែនការគ្រប់គ្រងឧទ្យានជាតិ ដែនជំរកសត្វព្រៃ តំបន់ការពារទេសភាព និង តំបន់ប្រើប្រាស់ច្រើនយ៉ាង ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ដូចមានចែងនៅក្នុងព្រះរាជក្រឹត្យ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងលើក សំណើស្តីពីការបង្កើតតំបន់ការពារធម្មជាតិថ្មីៗ បន្ថែមទៀត ។

_សហការ ពិគ្រោះ និងផ្តល់យោបល់ដល់ក្រសួងពាក់ព័ន្ធក្នុងកិច្ចការពារ និងអភិរក្សប្រព័ន្ធអេកូឡូស៊ី មានតំលៃដូចជា : តំបន់ដីសើម ទីជំរាល និងតំបន់ឆ្នេរ ដែល

ស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ និង នៅតំបន់ឯទៀតក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិ ។

_បំផុស និងជំរុញអោយមានការចូលរួមពីសំណាក់សហគមន៍មូលដ្ឋាន សាធារណៈជនទូទៅ ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលក្នុងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ។

_រៀបចំ និងអនុវត្តអនុក្រឹត្យ ព្រមទាំងបរិធានច្បាប់នានា សំរាប់កិច្ចការគ្រប់គ្រងតំបន់ការពារធម្មជាតិ ។

_អនុវត្តការផាកពិន័យអន្តរការណ៍ និង បទបញ្ញត្តិនានាដូចមានចែងក្នុងជំពូកទី៩ នៃច្បាប់ស្តីពីកិច្ច ការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

មាត្រា៨.. នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន មានភារកិច្ចសហការជាមួយនាយកដ្ឋានជំនាញដើម្បី :

_បំពេញកិច្ចការជំនាញពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារអន្តរជាតិនានាស្តីពីកិច្ចការពារគុណភាពបរិស្ថាន ។

_ចងក្រងបញ្ជីសារពើភ័ណ្ឌដែលបញ្ជាក់ពីប្រភព ប្រភេទ និងបរិមាណនៃសំណល់រឹង រាវ សារធាតុបំពុល សារធាតុពុល សារធាតុប្រកបដោយគ្រោះថ្នាក់ ផ្សែងសំឡេង និងរំញ័រ ។

_រៀបចំ និងអនុវត្តអនុក្រឹត្យ ព្រមទាំងបរិធានច្បាប់នានាសំរាប់កិច្ចការពារគុណភាពបរិស្ថាន និងត្រួតពិនិត្យការបំពុលនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

_អង្កេតតាមដាន ធ្វើរបាយការណ៍ និង ផ្សព្វផ្សាយពីស្ថានភាពគុណភាពបរិស្ថានរួមមានស្ថានភាពបំពុល ខ្យល់ ទឹក ដី និងសំឡេងជូនសាធារណជន ។

_រៀបចំសំណើ ស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ចលើប្រភពបំពុល និងការធ្វើរបាយការណ៍ស្តីពីបទល្មើសជូនស្ថាប័នមានសមត្ថកិច្ច ។

_អនុវត្តការធ្វើអធិការកិច្ចលើប្រភពបំពុល និងធ្វើរបាយការណ៍ ស្តីពីបទល្មើសជូនស្ថាប័នមានសមត្ថកិច្ច ដោយសហការជាមួយក្រសួងពាក់ព័ន្ធ ។

_អនុវត្តការងារផាកពិន័យអន្តរការណ៍និងបទបញ្ញត្តិនានាដូចមានចែងក្នុងជំពូកទី៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

មាត្រា ៩._នាយកដ្ឋានវាយតំលៃធនធានធម្មជាតិ និង គ្រប់គ្រងទិន្នន័យបរិស្ថាន មានភារកិច្ចសហការជាមួយ នាយកដ្ឋានជំនាញ និងស្ថាប័នពាក់ព័ន្ធដើម្បី :

_ប្រមែប្រមូល វិភាគ និងគ្រប់គ្រងទិន្នន័យស្តីពីធនធានធម្មជាតិ គុណភាពបរិស្ថាន និងសេដ្ឋកិច្ចសង្គមដែលពាក់ព័ន្ធ ។

_កំណត់ស្ថានភាព និង និន្នាការផ្លាស់ប្តូរនៅក្នុងធនធានធម្មជាតិ គុណភាពបរិស្ថាន និងសេដ្ឋកិច្ចសង្គម ដែលពាក់ព័ន្ធ ។

_ផ្តល់ទិន្នន័យ និងពតិមានស្តីពីធនធានធម្មជាតិ ធនធានសេដ្ឋកិច្ចសង្គម និង គុណភាពបរិស្ថានដល់ នាយកដ្ឋានជំនាញ និងស្ថាប័ននានាដែលពាក់ព័ន្ធ ។

_រៀបចំរបាយការណ៍ប្រចាំឆ្នាំ ស្តីអំពីស្ថានភាពបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា និងរបាយការណ៍ផ្សេងទៀត ដែលចាំបាច់សំរាប់រាជរដ្ឋាភិបាល ក្នុងការបំពេញ កាតព្វកិច្ច និងការទទួលខុសត្រូវដែលទាក់ទងនឹងកិច្ចព្រមព្រៀង អនុសញ្ញា និង ពិធីសារអន្តរជាតិនានា ស្តីពីកិច្ចការពារបរិស្ថាន ។

មាត្រា១០._នាយកដ្ឋានអប់រំ ពតិមាន និងផ្សព្វផ្សាយបរិស្ថាន មានភារកិច្ចសហការជាមួយនាយកដ្ឋានជំនាញ និងស្ថាប័នពាក់ព័ន្ធដើម្បី :

_តាក់តែង និងអនុវត្តកម្មវិធីអប់រំបរិស្ថានសំរាប់គ្រប់ស្រទាប់នៃសង្គម ។

_ចងក្រង និងផ្សព្វផ្សាយពតិមាន ស្តីពីបញ្ហាបរិស្ថាន ស្ថានភាពបរិស្ថាន និងសកម្មភាពការពារបរិស្ថាននានា តាមរយៈបណ្តាញផ្សព្វផ្សាយ ការបោះពុម្ព ។ល។

_ជំរុញការធ្វើសកម្មភាព និង យុទ្ធនាការនានាសំដៅលើកទឹកចិត្តដល់សាធារណជនអោយចូលរួមក្នុងកិច្ច ការពារគុណភាពបរិស្ថាន និងអភិរក្សធនធានធម្មជាតិ ។

_ផ្តួចផ្តើមគំនិត និង សំរបសំរួលវគ្គបណ្តុះបណ្តាលបរិស្ថាននានា ទាំងនៅក្នុងក្រសួងបរិស្ថាន ឬជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធដទៃទៀត ។

_រៀបចំ និង អនុវត្តអនុក្រឹត្យ ព្រមទាំងបរិធានច្បាប់នានាសំរាប់ការចូលរួមរបស់សាធារណជន និងការស្រង់យកពតិមាន ។

មាត្រា១១._នាយកដ្ឋានអង្កេតពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន មានភារកិច្ចសហការជាមួយនាយកដ្ឋានជំនាញ និងស្ថាប័នពាក់ព័ន្ធដើម្បី :

_ពិនិត្យឡើងវិញលើការវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គំរោង និងសកម្មភាពអភិវឌ្ឍន៍នានារបស់ ឯកជនឬសាធារណៈដែលមានស្រាប់ និងកំពុងដំណើរការ និងផ្តល់យោបល់ទៅស្ថាប័នមានសមត្ថកិច្ច។

_រៀបចំអនុក្រឹត្យ ស្តីពីបែបបទនៃកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់រាជរដ្ឋាភិបាល ។

_រៀបចំបញ្ជីដែលកំណត់ប្រភេទ ទំហំគំរោង និង សកម្មភាពដែលត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

_រៀបចំគោលការណ៍ណែនាំ ស្តីពីការធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

_ជំរុញអោយមានការចូលរួមពីសាធារណជនក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

_អង្កេតតាមដានការអនុវត្តន៍គំរោងសំដៅកាត់បន្ថយហេតុប៉ះពាល់បរិស្ថានជាអវិជ្ជមាន ។

ជំពូក ៤

អធិការដ្ឋាន

មាត្រា ១២._អធិការដ្ឋានរបស់ក្រសួងបរិស្ថានទទួលបន្ទុក :

_ធ្វើអធិការកិច្ចជាប្រចាំទៅលើអង្គភាពក្រោមឱវាទក្រសួងបរិស្ថាន ។

_ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីពីការប្រព្រឹត្តិទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយនោះ និងពី មធ្យោបាយកែលំអការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនោះ ។

_ប្រតិបត្តិភារកិច្ចតាមកាលដែលរដ្ឋមន្ត្រីបានប្រគល់ទុកចិត្ត ។

_អធិការដ្ឋានដឹកនាំដោយអធិការមួយរូប អមដោយអធិការរងជាជំនួយការ តាមការចាំបាច់ ។

ជំពូក ៥

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច

មាត្រា ១៣._នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុទទួលបន្ទុក :

ក_ក្នុងវិស័យរដ្ឋបាលទូទៅ និងសរុប

_សំរបសំរួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាព មូលដ្ឋានក្រោមឱវាទ ។

_គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។

_ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល ។

_សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង ។

ខ_ក្នុងវិស័យគ្រប់គ្រងបុគ្គលិក

_គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការក្រសួង ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការ ដ្ឋានមុខងារសាធារណៈ ។

_រៀបចំលិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព ។

_ធ្វើកម្មវិធីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង ។

_វាយតំលៃតំរូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក ។

_រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្តដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការ-ដ្ឋានមុខងារសាធារណៈ និងអនុវត្តនយោបាយនោះ ។

_រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពត៌មានប្រតិបត្តិ ។

_គ្រប់គ្រងការងារសង្គមរបស់ក្រសួង ។

គ_ក្នុងវិស័យគ្រប់គ្រងសំភារៈ និងបរិក្ខារ

_ប្រមូលផ្តុំតំរូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំផ្គូសជុលសំភារៈ និងបរិក្ខាររបស់ក្រសួង។

_គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ ។

_គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់ ។

_គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់ ។

_ទទួល និងបែងចែកបរិក្ខារជូនដល់បណ្តាអង្គភាពខេត្ត_ក្រុងនានា ។

_កាន់បញ្ជីជាប្រចាំនូវសលាកប័ត្រ និងគណនេយ្យរូបធាតុ ។

_ពតិមានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។

_ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។

ឃ_ក្នុងវិស័យគ្រប់គ្រងបន្ទុកគណនី និងហិរញ្ញវត្ថុ

_លើកគំរោងថវិកាក្រសួង និងតាមដានរំលឹកពីការប្រតិបត្តិ ។

_ប្រមូលចំណូលអោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ ។

_ប្រមូលផ្តុំ និងសំរបសំរួលជំពូកថវិកា ។

_តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស ។

_ប្រមូលផ្តុំ និងសំរបសំរួលរាល់ចំណាយរបស់ក្រសួង ។

_គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តន៏លទ្ធកម្មសាធារណៈ ។

ជំពូក ៦

ខុទ្ទកាល័យរដ្ឋមន្ត្រី

មាត្រា ១៤._ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកការងារទាំងឡាយ ដែលកំណត់តាមបទបញ្ញត្តិ នៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

ជំពូក ៧

អង្គភាពមូលដ្ឋាន

មាត្រា ១៥._នៅតាមខេត្ត_ក្រុងនីមួយៗ មានមន្ទីរបរិស្ថានខេត្ត_ក្រុង នៅតាមស្រុក_ខ័ណ្ឌមានភ្នាក់ងារបរិស្ថាន ស្រុក_ខ័ណ្ឌ ។ មន្ទីរបរិស្ថានខេត្ត_ក្រុង និង ភ្នាក់ងារបរិស្ថានស្រុក_ខ័ណ្ឌ ទទួលបន្ទុកអនុវត្ត និង សំរបសំរួលសកម្មភាពរបស់ក្រសួង ។

ជំពូក ៨

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា ១៦._អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបង្កើតឡើង ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ជាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

ជំពូក ៩

អវសានបញ្ញត្តិ

មាត្រា ១៧._ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាលចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន ។

មាត្រា ១៨._បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៩._សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ។

មាត្រា ២០._អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ហត្ថលេខា និងត្រា	ហត្ថលេខានិងត្រា
អ៊ឹង ហួត	**ហ៊ុន សែន**

* * *

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧

អង្គការលេខ របស់ក្រសួងបរិស្ថាន



អនុក្រឹត្យលេខ ៥៨ អនក្រ.បក

ស្តីពី

ការបង្កើតគណៈកម្មាធិការជាតិសំរប សំរួលការងារអប់រំក្រៅប្រព័ន្ធ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ សន/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា
- បានការអនុម័តរបស់គណៈរដ្ឋមន្ត្រីនាសម័យប្រជុំថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ១៩៩៧

សំរេច

មាត្រា ១.- បង្កើតគណៈកម្មាធិការជាតិសំរបសំរួល ការងារអប់រំក្រៅប្រព័ន្ធ ដែលហៅកាត់ថា « គ.ជ.អ.ក.ប » ។

មាត្រា ២ .- គណៈកម្មាធិការនេះមានគោលបំណងសំរបសំរួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធអោយបានល្អប្រសើរ ដើម្បីជំរុញការងារអប់រំក្រៅប្រព័ន្ធ ដែលរួមមានការបំបាត់អនក្ខរភាព ការផ្តល់ការអប់រំមូលដ្ឋាន និងការបណ្តុះបណ្តាលវិជ្ជាជីវៈអោយមានការរីកចំរើន រួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកំពស់គុណភាពនៃ

ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ អភិវឌ្ឍន៍ធនធានមនុស្ស និងអភិវឌ្ឍន៍ប្រទេសជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

មាត្រា ៣ .- សមាសភាពនៃគណៈកម្មាធិការជាតិ សំរបសំរួលការងារអប់រំក្រៅប្រព័ន្ធរួមមាន ÷

១_ នាយករដ្ឋមន្ត្រី...ប្រធានកិត្តិយស

២_ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា .... ប្រធាន

៣_ រដ្ឋលេខាធិការក្រសួងអប់ យុវជន និងកីឡា.................អនុប្រធាន

៤_ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ .... សមាជិក

៥_ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី .... សមាជិក

៦_ តំណាងក្រសួងការពារជាតិ .... សមាជិក

៧_ តំណាងក្រសួងផែនការ... .... សមាជិក

៨_ តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ .... សមាជិក

៩_ តំណាងក្រសួងអភិវឌ្ឍន៍ជនបទ............................. សមាជិក

១០_ តំណាងក្រសួងកិច្ចការនារី... ....សមាជិក

១១_ តំណាងក្រសួងសុខាភិបាល.. ....សមាជិក

១២_ តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ............ សមាជិក

១៣_ តំណាងក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន.......... សមាជិក

១៤_ តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល .... សមាជិក

១៥_ តំណាងក្រសួងបរិស្ថាន..... .... សមាជិក

១៦_ តំណាងក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ...................... សមាជិក

១៧_ តំណាងក្រសួងពត៌មាន..... .... សមាជិក

១៨_ តំណាងក្រសួងធម្មការ និង កិច្ចការសាសនា.................. សមាជិក

មាត្រា ៤.- គណៈកម្មាធិការជាតិសំរបសំរួលការងារអប់រំក្រៅប្រព័ន្ធ មាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និង កីឡា ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៥.- គណៈកម្មាធិការជាតិសំរបសំរួល ការងារអប់រំក្រៅប្រព័ន្ធមានភារកិច្ច ÷

- រៀបចំគោលនយោបាយជាតិ ស្តីពីការអប់រំក្រៅប្រព័ន្ធ ។

- លើកផែនការ និងកំណត់គោលដៅនៃការអប់រំក្រៅប្រព័ន្ធ ។
- ដាក់ចុះនូវយុទ្ធសាស្ត្រសំរាប់ទ្រទ្រង់សកម្មភាពនៃកម្មវិធីអប់រំក្រៅប្រព័ន្ធ ។
- សំរបសំរួល ទាក់ទង និង រៀបចំបង្កើតបណ្តាញជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ផ្នែកឯកជន និង សប្បុរសជន ដើម្បីចលនាប្រើប្រាស់ធនធាន ទាំងធនធានមនុស្ស ទាំងធនធានសំភារៈ និង ថវិកាក្នុងការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ ដោយអាចអញ្ជើញសមាសភាពពាក់ព័ន្ធទាំងនេះចូលរួមប្រជុំតាមការចាំបាច់ ។
- រៀបចំយុទ្ធសាស្ត្រសំរាប់ស្នើសុំការចូលរួមរបស់សហគមន៍ ។
- តាមដាន និងវាយតំលៃការរីកចំរើនរបស់ការងារអប់រំក្រៅប្រព័ន្ធ ដោយយកចិត្តទុកដាក់ជាពិសេសចំពោះក្រុមជនដែលជួបការលំបាក ។

មាត្រា ៦.- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ សំរបសំរួលការងារអប់រំក្រៅប្រព័ន្ធមានភារកិច្ច ៖

- លើកកំពស់គុណភាព ប្រសិទ្ធភាពការងារបច្ចេកទេស សិក្សាស្រាវជ្រាវគោលនយោបាយអន្តរជាតិ និងបទពិសោធន៍ស្តីពីការងារអប់រំក្រៅប្រព័ន្ធ ។
- រៀបចំពង្រាងគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រផ្សេងៗដាក់ជូនគណៈកម្មាធិការជាតិសំរបសំរួលការងារអប់រំក្រៅប្រព័ន្ធ ។
- ធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធអង្គការក្រៅរដ្ឋាភិបាល និង អង្គការអន្តរ ជាតិដែលបាននិងកំពុងជួយទ្រទ្រង់យ៉ាងសកម្ម ដល់ការងារអប់រំក្រៅប្រព័ន្ធ ។
- រៀបចំការប្រជុំរបស់គណៈកម្មាធិការជាតិ សំរបសំរួលការងារអប់រំក្រៅប្រព័ន្ធ និងអនុវត្តរាល់សេចក្តីសំរេចចិត្ត របស់អង្គប្រជុំនៃគណៈកម្មាធិការនេះ ។

មាត្រា ៧.- នៅតាមបណ្តាខេត្ត/ក្រុង ស្រុក/ខ័ណ្ឌ ឃុំ/សង្កាត់ ត្រូវបង្កើតអោយមានគណៈកម្មាធិការសំរបសំរួលការងារអប់រំក្រៅប្រព័ន្ធថ្នាក់ខេត្ត/ក្រុង ស្រុក/ខ័ណ្ឌ ឃុំ/សង្កាត់ ។

ក_សមាសភាពនៃគណៈកម្មាធិការសំរបសំរួលការងារអប់រំក្រៅប្រព័ន្ធខេត្ត/ក្រុង រួមមាន អភិបាលខេត្ត/ក្រុងជាប្រធាន ប្រធានមន្ទីរអប់រំយុវជន និងកីឡា ជា

=

អនុប្រធាន ប្រធានមន្ទីរពាក់ព័ន្ធជាសមាជិក ការិយាល័យអប់រំក្រៅប្រព័ន្ធជាលេខាធិការអចិន្ត្រៃយ៍ ។

ខ_សមាសភាពនៃគណៈកម្មាធិការសំរបសំរួលការងារអប់រំក្រៅប្រព័ន្ធ ស្រុក/ខ័ណ្ឌ រួមមាន អភិបាលស្រុក/ខ័ណ្ឌជាប្រធាន ប្រធានការិយាល័យអប់រំ យុវជន និងកីឡាជាអនុប្រធាន ប្រធានការិយាល័យពាក់ព័ន្ធជាសមាជិក ផ្នែកអប់រំក្រៅប្រព័ន្ធជាលេខាធិការដ្ឋានអចិន្ត្រៃយ៍ ។

គ_សមាសភាពនៃគណៈកម្មាធិការ សំរបសំរួលការងារអប់រំក្រៅប្រព័ន្ធឃុំ/សង្កាត់ រួមមាន មេឃុំ/ចៅសង្កាត់ជាប្រធាន មន្ត្រីអប់រំក្រៅប្រព័ន្ធឃុំ/សង្កាត់ ជាអនុប្រធាន នាយកកំរងសាលាបឋមសិក្សា និងមេភូមិ ជាសមាជិក ។

មាត្រា ៨ ._ តួនាទី ភារកិច្ច និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការ ខេត្ត/ក្រុង ស្រុក/ខ័ណ្ឌ ឃុំ/សង្កាត់ អាស្រ័យដោយគណៈកម្មាធិការជាតិ សំរបសំរួលការងារអប់រំក្រៅប្រព័ន្ធជាអ្នកកំណត់ ។ គណៈកម្មាធិការសំរបសំរួល ការងារអប់រំក្រៅប្រព័ន្ធខេត្ត/ក្រុង ស្រុក/ខ័ណ្ឌ ឃុំ/សង្កាត់ អាចអញ្ជើញអង្គការក្រៅរដ្ឋាភិបាល សមាគម ផ្នែកឯកជន និងសប្បុរសជន អោយចូលរួមអនុវត្តការងារនេះ ។

មាត្រា ៩ ._ ថវិការបស់គណៈកម្មាធិការជាតិ សំរបសំរួលការងារអប់រំក្រៅប្រព័ន្ធ ត្រូវបានផ្តល់ដោយថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា និងការឧបត្ថម្ភពីប្រភពផ្សេងៗ។

មាត្រា ១០._ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១១._ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត/ក្រុង គណៈកម្មាធិការជាតិសំរបសំរួល ការងារអប់រំក្រៅប្រព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា	ហត្ថលេខានិងត្រា
អ៊ុង ហួត	**ហ៊ុន សែន**

អនុក្រឹត្យលេខ ១៨១ អនក្រ.តត
ស្តីពីការប្រគល់ឋានន្តរសក្តិកិត្តិយស

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

– បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៨៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

– យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ .– ត្រូវបានប្រគល់ឋានន្តរសក្តិកិត្តិយសថ្នាក់ វរសេនិយឯក ដែលមានរាយនាមដូចខាងក្រោម ÷

១_លោក រំចេក សុខារី ២_លោក ញ៉ឹក សារ៉ឹម

៣_លោក ទ៊ាន់ មិន ៤_លោក គី ខូ

៥_លោក ប៊ិត់ សារិន ៦_លោកស្រី យក់ ណារ៉េត

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា	ហត្ថលេខានិងត្រា
អ៊ឹង ហួត	**ហ៊ុន សែន**

* * *

អនុក្រឹត្យលេខ ១៨២ អនក្រ.តត
ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ .. ផ្លាស់លោកស្រី **កែវ ម៉ុនឈួត** ទីប្រឹក្សាអមស្ថានឯកអគ្គរាជទូត នៃព្រះរាជា_ណាចក្រកម្ពុជា នៅទីក្រុងវ៉ាស៊ីនតោន អោយមកបំរើការងារនៅក្នុងប្រទេសវិញ ។

មាត្រា ២ .. សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការ នៃរដ្ឋ-លេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អគ្គលេខាធិការ នៃស្ថាប័នពាក់ព័ន្ធ និងលោកស្រី **កែវ ម៉ុនឈួត** ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ហត្ថលេខានិងត្រា	ហត្ថលេខានិងត្រា
អ៊ុង ហួត	**ហ៊ុន សែន**

* * *

អនុក្រឹត្យលេខ ១៨៣ អនក្រ.តត
ស្តីពីការ តែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីសមាសភាពក្រុមប្រឹក្សាភិបាលមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាល មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា និងរដ្ឋមន្ត្រីក្រសួងពត៌មាន

សំរេច

មាត្រា ១.- តែងតាំងឯកឧត្តម **ឆៀម ជុំឡុច** ជានាយករង មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ដែលមានឋានៈស្មើ អគ្គនាយករង ។

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាភិបាលមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា	ហត្ថលេខានិងត្រា
អ៊ុង ហួត	**ហ៊ុន សែន**

* * *

អនុក្រឹត្យលេខ ១០៤ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤

-ពិនិត្យសំណូមពរការងារ និងសមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

មាត្រា ១.- ត្រូវបានតែងតាំងលោក **សួន ចន្ថា** ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រីទី ២ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា	ហត្ថលេខានិងត្រា
អ៊ុង ហួត	**ហ៊ុន សែន**

* * *

អនុក្រឹត្យលេខ ១៨៥ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

០៥ ការ ១៩៩៤ រដ្ឋ_ ស្រួង និង ពីថ្ងៃ ព្រះ ការ ាស

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- យោងតាមសំណើរបស់ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១.- តែងតាំងលោក **ផ្លុង គឹមឡុន** ជាអភិបាលរងទី ១ ខេត្តបាត់ដំបង ជំនួស លោក **សេរី កុសល** ។

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈ អភិបាលខេត្តបាត់ដំបង និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា	ហត្ថលេខានិងត្រា
អ៊ុង ហួត	**ហ៊ុន សែន**

* * *

អនុក្រឹត្យលេខ ១៨៦ អនក្រ.តត

ស្តីពីការប្រគល់មេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

_បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

_តាមសំណើរបស់សមាគមនារីកម្ពុជា

សំរេច

មាត្រា ១._ ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិ ជូនលោកស្រី **ម៉ូនីកា វ៉ាន់ដឺរមៀរ** (MONIKA VANDER MEER) តំណាងអង្គការសេវាកម្ម ដើម្បីសាមគ្គីភាពអន្តរជាតិ អាល្លឺម៉ង់ " SODI" ដែលបានផ្តល់ថវិកាសំរាប់កសាងអាគារ សិក្សា ១ខ្នង និងផ្គត់ផ្គង់សំភារៈប្រើប្រាស់ប្រចាំថ្ងៃរបស់សិស្សរយៈពេល ២ឆ្នាំ អណ្តូងទឹកស្អាត ៥៥ និងផ្តល់ម៉ាស៊ីនបូមទឹកចំនួន ២៩ គ្រឿង ជូនប្រជាពលរដ្ឋ ក្នុងឃុំប្រកម្ពេស ស្រុកស្វាយទៀប ខេត្តស្វាយរៀង មានតំលៃសរុបទឹកប្រាក់ចំនួន ១៨៧.៤៩៤.៦៧០ រៀល ។

មាត្រា ២._សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធាន សមាគមនារីកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា	ហត្ថលេខានិងត្រា
អ៊ុង ហួត	**ហ៊ុន សែន**

* * *

អនុក្រឹត្យលេខ ១៨៧ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

សំរេច

មាត្រា ១.- ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិ ជូនសប្បុរសជនចំនួន ០៣រូប ដែលបានជួយកសាងសាលាបឋមសិក្សាតាយីង ក្នុងស្រុកសំរោង ខេត្តតាកែវ សរុបជាថវិកាអស់ ១០៩.៨៤៣ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម ÷

១_លោក **RON Maddux**	ប្រធានអង្គការ **Assemblies of GOD** ប្រចាំនៅអាស៊ី
២_លោក **BILL PREVETTE**	ប្រធានអង្គការ **Assemblies of GOD** ប្រចាំនៅកម្ពុជា
៣_ឯកឧត្តម **ឡុង វិសាលោ**	ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តតាកែវត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា	ហត្ថលេខានិងត្រា
អ៊ុង ហួត	**ហ៊ុន សែន**

* * *

អនុក្រឹត្យលេខ ១៤៨ អនក្រ.តត
ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

_បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

_តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

សម្រេច

មាត្រា ១._ ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិ ជូនសប្បុរសជនចំនួន ០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអាគារសិក្សាមួយខ្នងនៅក្នុងសាលាបឋមសិក្សាព្រៃកពក ឃុំថ្នាធ្នង់ ស្រុករំដួល ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម ÷

១_លោក ឧកញ៉ា **សៅ សេរីមន្នី** ហៅ **យ៉ាត** ទឹកប្រាក់ ១០.០០០ដុល្លារអាមេរិក

២_លោក **សៅ សុវណ្ណី** ទឹកប្រាក់ ១០.០០០ដុល្លារអាមេរិក

មាត្រា ២._ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខានិងត្រា ហត្ថលេខានិងត្រា

អ៊ុឹង ហួត **ហ៊ុន សែន**

អនុក្រឹត្យលេខ ១៨៩ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តតាកែវ

សំរេច

មាត្រា ១ .- ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិ ជូនចំពោះអង្គការស្ថាន **កម្ពុជា ហ្វូឡង់** ដែលបានជួយកសាងសាលាបឋមសិក្សា អង្គតាពៅ ក្នុងស្រុកសំរោង ខេត្តតាកែវ និងសាលាបឋមសិក្សា ឈើទាលជ្រុំ ស្រុកបាទី ខេត្តតាកែវ សរុបជាទឹកប្រាក់ចំនួន ៣៦.៦៤៣$US ។

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខានិងត្រា ហត្ថលេខានិងត្រា

អ៊ុឹង ហួត **ហ៊ុន សែន**

* * *

អនុក្រឹត្យលេខ ១៩០ អនក្រ.តត
ស្តីពីការជូនមេដាយ សហមេត្រី

* * *

រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

_បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

_តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

